# ព្រះធម៌អាថ៌កំបាំង

## *ភាគ១ ... ពីភាសាអារ៉ាប់*

ព្រះអង្គទ្រង់ជាភាពរុងរឿង លើភាពរុងរឿងទាំងពួង

បន្ទបន្ទាប់តទៅនេះ គឺជាព្រះធម៌មកពីព្រះរាជាណាចក្រនៃភាពរុងរឿង ត្រាស់បញ្ចេញដោយព្រះសូរសៀងដ៏ទ្រង់រិទ្ធិ និងទ្រង់ចេស្ដា ហើយក៏ធ្លាប់សំដែងដោយ ព្រះសាស្ដាគ្រប់ព្រះអង្គកាលពីអតីតកាលដែរ ។ យើងបាននាំខ្លឹមសារនៃធម៌ទាំងនេះ មកចងក្រងជាកម្រងក្លែបខ្លីៗ ទុកជានិមិត្តរូបនៃក្ដីករុណាដល់អ្នកប្រតិបត្តិធម៌ទាំងអស់ ដើម្បីអោយអ្នកប្រតិបត្តិធម៌ទាំងនោះ បានប្រកាន់ខ្ជាប់ក្នុងបដិញ្ញារបស់ព្រះជាម្ចាស់ និងបានសំរេចដល់គុណធម៌ទិព្វក្នុងពិភពនៃវិញ្ញាណ ។

## ១-ម្នាលបុត្រនៃធម៌អើយ!

បរមឱវាទដំបូងរបស់យើងនេះគឺៈ ចូរមានចិត្តបរិសុទ្ធ មេត្តា និងជ្រះថ្លាដើម្បីអោយដួងចិត្តរបស់អ្នក អាចមានអធិបតេយ្យភាពមួយ ដ៏ថិតថេរនិងចិរកាលជានិច្ចនិរន្តរ៍ ។

## ២- ម្នាលបុត្រនៃធម៌អើយ!

វត្ថុដ៏ជាទីស្រឡាញ់នៃក្រសែចក្ខុរបស់យើង គឺសេចក្តីយុត្តិធម៌ ចូរអ្នកកុំងាកចេញពីវត្ថុនេះបើអ្នកប្រាថ្នាយើង និងកុំធ្វេសប្រហែស ទើបយើងអាចទុកចិត្តអ្នកបាន ។ ដោយសេចក្តីយុត្តិធម៌នេះ អ្នកនឹងបានឃើញដោយផ្ទាល់ភ្នែករបស់អ្នកមិនមែនតាមរយៈភ្នែករបស់អ្នកដទៃនិងយល់ដោយសតិបញ្ញារបស់អ្នក មិនមែនតាមរយៈសតិបញ្ញានៃញាតិមិត្តរបស់អ្នកឡើយ ។ ចូរអ្នកសញ្ជឹងគិតមើលទៅតើវាប្រសើរអស្ចារ្យប៉ុណ្ណាសំរាប់អ្នក។ ពិតប្រាកដណាស់សេចក្តីយុត្តិធម៌នេះ គឺជាអំណោយរបស់យើងសំរាប់អ្នក និងជានិមិត្តរូបនៃសេចក្តីស្រឡាញ់ប្រតិពទ្ធ៍របស់យើង ។ ចូរអ្នកដាក់អោយចំពីមុខរបស់អ្នក ។

## ៣– ម្នាលបុត្រនៃមនុស្សអើយ!

ដោយយើងបានស្ថិតនៅក្នុងភាពអមតៈ និងក្នុងខ្លឹមសារអនន្ត របស់យើង ។ យើងបានញាណដល់ការស្រឡាញ់រូបអ្នក ដូច្នេះ ហើយ បានជាយើងបង្កើតរូបអ្នកឡើងមក ចារឹករូបសំណាករបស់ យើងក្នុងដួងចិត្តរបស់អ្នក ព្រមទាំងសំដែងអោយបានឃើញនូវ សោភ័ណភាពរបស់យើង។

## ៤– ម្នាលបុត្រនៃមនុស្សអើយ!

យើងស្រលាញ់ការបង្កើតរូបអ្នកទើបយើងបង្កើតរូបអ្នកឡើង មក ដូច្នេះអ្នកត្រូវតែស្រលាញ់យើង ទើបយើងអាចចារឹកឈ្មោះ របស់អ្នក និងប្រសិទ្ធីព្រលឹងរបស់អ្នក ដោយវិញ្ញាណនៃជីវិត ។

## ៥– ម្នាលបុត្រនៃមនុស្សអើយ!

អ្នកត្រូវតែស្រលាញ់យើង ទើបយើងអាចប្រតិព័ទ្ធអ្នកវិញបាន បើអ្នកមិនស្រឡាញ់យើង សេចក្ដីប្រតិព័ទ្ធរបស់យើងមិនអាចកើត មានដល់អ្នកបានឡើយ ។ ចូរចាំអោយជាក់ណាសាវក័អើយ ។

## ៦- ម្នាលបុត្រនៃជីវិតអើយ!

ឋានសួគ៌របស់អ្នក គឺសេចក្ដីស្រលាញ់របស់យើងឯវិមានដ៏រុងរឿងរបស់អ្នក គឺការវិលត្រឡប់មករួមរស់ជាមួយយើង ។ ចូរប្រញាប់មកនិងគប្បីកុំរារែក ព្រោះវត្ថុនេះហើយត្រូវបានកំណត់សំរាប់អ្នកពីអាណាចក្រខាងលើដ៏ឧត្ដមរបស់យើង ។

## ៧- ម្នាលនៃមនុស្សអើយ!

បើអ្នកស្រឡាញ់រូបយើង ចូរងាកអោយឆ្ងាយពីខ្លួនរបស់អ្នក និងប្រសិនបើអ្នកស្វែងរកសេចក្ដីសុខរបស់យើង ចូរកុំគិតពីប្រាណរបស់អ្នក ទើបអ្នកអាចស្លាប់ក្នុងនាមរបស់យើង ហើយយើងអាចស្ថិតនៅជាមួយអ្នកបានជានិរន្តរ ។

## ៨- ម្នាលបុត្រនៃធម៌អើយ!

គ្មានទេសេចក្ដីសុខសំរាប់អ្នក លើកលែងតែអ្នកលះបង់ពីខ្លួនរបស់អ្នកហើយវិលត្រឡប់មករកយើងព្រោះវាជាការចាំបាច់ណាស់ដែលអ្នកត្រូវតែរុងរឿងក្នុងជីវិតរបស់យើង ប្រសើរជាងខ្លួនរបស់

អ្នកនិងជឿទុកចិត្តលើយើងជៀសជាងទុកចិត្តលើខ្លួនឯង។ ព្រោះយើងជាអ្នកកំណត់នៃវត្ថុទាំងពួង ។

## ៩- ម្នាលបុត្រនៃជីវិតអើយ!

សេចក្ដីស្រឡាញ់របស់យើងគឺជាកំពែងការពាររបស់អ្នក អ្នកដែលចូលមកប្រាកដជាបានសុខនិងសុវត្ថិភាព ចំពោះអ្នកដែលប្រែប្រាណទៅឆ្ងាយនឹងត្រូវវង្វេងផ្លូវព្រមទាំងអន្តរាយជាក់ជាមិនខាន។

## ១០- ម្នាលបុត្រនៃឱវាទអើយ!

អ្នកជាកំពែងការពារដ៏រឹងមាំរបស់យើង ចូរអ្នកចូលមកទើបអ្នកអាចស្នាក់ក្នុងសុវត្ថិភាព ឯសេចក្ដីស្រឡាញ់របស់យើងដែលមាននៅក្នុងខ្លួនរបស់អ្នក ចូរអ្នកចាំទុកថា: គឺដើម្បីអោយអ្នកបានឃើញយើងនៅក្បែរខ្លួនរបស់អ្នក ។

## ១១- ម្នាលបុត្រនៃជីវិតអើយ!

អ្នកជាប្រទីបរបស់យើង ឯភ្លើងរបស់យើងស្ថិតនៅក្នុងខ្លួនរបស់អ្នក ចូរអ្នកបំភ្លឺវាចេញទៅនិងកុំនៅស្វែងរកពីអ្នកដទៃណា

ទៀត ។ ព្រោះយើងបានបង្កើតអ្នកឡើងមកយ៉ាងឧត្តមនិងស្រោចស្រប់មេត្តាធម៌ដ៏សម្បូណ៌ហើយដែរ ។

## ១២- ម្នាលបុត្រនៃជីវិតអើយ!

យើងបានបង្កើតអ្នកឡើងដោយហត្ថដ៏ទ្រង់អានុភាព និងតាក់តែងរូបអ្នកដោយអង្គុលីដ៏ទ្រង់រិទ្ធិ និងនៅក្នុងខ្លួនរបស់អ្នក យើងបានដាក់នូវខ្លឹមសារនៃពន្លឺរបស់យើង ។ ចូរអ្នកពេញចិត្តនិងកុំនឹកស្វែងរកពីអ្នកដទៃណាទៀត ។ ព្រោះការងាររបស់យើង វាបានសុក្រឹតនិងបញ្ញត្តិរបស់យើងក៏ត្រូវកំពុងអនុវត្តហើយដែរ ។ ចូរកុំកង្វល់និងមន្ទិលធ្វើអ្វីឡើយ ។

## ១៣- ម្នាលបុត្រនៃធម៌អើយ!

យើងបានបង្កើតអ្នកឡើងមកយ៉ាងសម្បូណ៌បំផុត ម្ដេចក៏អ្នកនាំប្រាណអោយក្រក្រី? យើងបានតាក់តែងរូបអ្នកឡើងមកយ៉ាងឧត្តម ម្ដេចក៏អ្នកបន្ថោកខ្លួនទៅវិញ? យើងបានផ្ដល់ជីវិតអ្នកមកពីមន្តវិជ្ជាដ៏ពិសិដ្ឋ ម្ដេចក៏អ្នកទៅស្វែងរកវិជ្ជាពីអ្នកដទៃទៅវិញ ? យើងបានសូន្យរូបអ្នកឡើងមកពីមត្តិកានៃសេចក្ដីស្រឡាញ់ តើអ្នក

អំពល់ប្រាណជាមួយអ្នកដទៃបានដោយរបៀបណា? ចូរបែរចក្ខុរបស់អ្នកមកកាន់រូបអ្នក នោះអ្នកនឹងបានឃើញយើងស្ថិតនៅជាមួយអ្នក ដោយតេជះស្តា និងគង់នៅដោយបារមីនៃអង្គឯង ។

## ១៨– ម្នាលបុត្រនៃមនុស្សអើយ!

អ្នកជាអាណាចក្ររបស់យើង អាណាចក្ររបស់យើងមិនអាចសាបសូន្យបានឡើយ ។ អ្នកជាភាពរុងរឿងរបស់យើងនឹងមិនព្រិលស្រអាប់បានឡើយ អ្នកជាភាពរុងរឿងរបស់យើង ភាពរុងរឿងរបស់យើងមិនអាចសាករលប់បានឡើយ ។ អ្នកជាសំលៀកបំពាក់របស់យើង ។ ដូច្នេះចូរអ្នកដាក់នូវសេចក្តីប្រតិព័ទ្ធរបស់អ្នកចំពោះយើង ទើបអ្នកអាចមាននិស្ស័យបានជួបយើង ក្នុងភពនៃភាពរុងរឿង ។

## ១៥– ម្នាលបុត្រនៃឱវាទអើយ!

ចូរងាកមុខរបស់អ្នកមករកយើងហើយលះបង់អោយអស់ពីវត្ថុទាំងឡាយក្រៅពីរូបយើង ព្រោះអធិបតេយ្យភាពរបស់យើងបិតថេរជានិច្ច ឯអាណាចក្ររបស់យើងក៏មិនអាចសាបសូន្យបានដែរ។

បើអ្នកស្វែងរកពីអ្នកដទៃ ទោះអស់អសង្ខៃទូទាំងចក្រវាឡ ក៏ការរុករករបស់អ្នកគ្មានប្រយោជន៍ដែរ ។

## ១៦- ម្នាលបុត្រនៃពន្លឺអើយ!

ចូរអ្នកបំភ្លេចអោយអស់នូវសព្វវត្ថុទាំងឡាយ ក្រៅពីរូបយើង ហើយបែរមកប្រាស្រ័យទាក់ទងជាមួយវិញ្ញាណរបស់យើង។នេះជាបញ្ញត្តិធម៌របស់យើង ដែលអ្នកត្រូវប្រតិបត្តិតាម ។

## ១៧- ម្នាលបុត្រនៃមនុស្សអើយ!

ចូរពេញចិត្តចំពោះយើង និងកុំស្វែងរកជនអនុកូលដទៃណាទៀត ព្រោះគ្មានអ្នកណាមួយអាចធ្វើអោយអ្នកបានស្កប់ ក្រៅពីរូបយើងឡើយ ។

## ១៨- ម្នាលបុត្រនៃធម៌អើយ!

កុំប្រាថ្នាអ្វីដែលយើងមិនបំណងអោយតែចូរពេញចិត្តជាមួយអ្វីដែលយើងកំណត់អោយ ព្រោះវត្ថុនេះហើយ ជាគុណប្រយោជន៍របស់អ្នក បើអ្នកអនុវត្តតាម ។

## ១៩-　ម្នាលបុត្រនៃឧត្តមទស្សនះ!

យើងបានផ្តល់ដង្ហើមទៅក្នុងខ្លួនរបស់អ្នកជាដង្ហើមនៃវិញ្ញាណរបស់យើងដើម្បីអោយអ្នកបានក្លាយជាមនុស្សជាទីស្រឡាញ់របស់យើង។ ហេតុអ្វីក៏អ្នកប្រះប្រាណពីយើង ទៅស្វែងរកអ្នកដទៃទៅវិញ?

## ២០-　ម្នាលបុត្រនៃធម៌អើយ!

ការអះអាងរបស់យើងដែលមានចំពោះអ្នក ក្រាស់ក្រែលកន្លងមិនអាចបំភ្លេចបានឡើយ។ ហើយសេចក្តីករុណារបស់យើងដែលមានចំពោះអ្នកនោះ ក៏ក្រៃសម្បូរណ៍មិនអាចបិទបាំងបានឡើយ និងសេចក្តីស្រឡាញ់របស់យើង ដែលបានបង្កើតជាគេហដ្ឋានក្នុងខ្លួនរបស់អ្នកនោះ ក៏មិនអាចលាក់បាំងបានដែរ ឯរស្មីដែលបានចែងចាំងទៅដល់អ្នកក៏មិនអាចស្រអាប់បានដែរ ។

## ២១-　ម្នាលបុត្រនៃមនុស្សអើយ

លើដើមព្រឹក្សានៃភាពរុងរឿងដ៏ត្រកាល យើងបានសំរាំងនូវផ្លែឈើដ៏ប្រណិតសំរាប់អ្នក ម្តេចក៏អ្នកងាកចេញទៅពេញចិត្តជា

មួយផ្លែក្រៀមស្វិតទៅវិញ? ចូរអ្នកប្រញាប់ត្រឡប់មករកអ្វីដែលប្រសើរឧត្តមសំរាប់អ្នក ក្នុងអាណាចក្រខាងលើ ។

## ២២- ម្នាលបុត្រនៃធម៌អើយ!

យើងបានបង្កើតអ្នកឡើងមកយ៉ាងឧត្តម តែអ្នកបែរជាបន្ថោកខ្លួនទៅវិញ ។ ចូរអ្នកក្រោកឡើងមកអោយសមឋានៈដែលអ្នកត្រូវបានបង្កើតឡើង ។

## ២៣- ម្នាលបុត្រនៃភាពឧត្តមអើយ!

យើងបានដង្ហោយហៅអ្នកទៅកាន់ធម្មសាលា តែអ្នកបែរជាទៅស្វែងរកសំណាក់អនន្តាទៅវិញ។ តើអ្វីទៅបណ្ដាលអោយអ្នកប្រាស់ចាកពីសេចក្ដីប្រាថ្នារបស់យើង ទៅតាមទំនើងចិត្តរបស់ខ្លួន?

## ២៤- ម្នាលបុត្រនៃមនុស្សអើយ!

ចូរកុំបំពានលើក្រមរបស់ខ្លួន និងកុំអះអាងអ្វីដែលមិនសមសំរាប់អ្នក តែចូរអភិវន្ទនាចំពោះព្រះភក្ត្រនៃព្រះជាម្ចាស់ដ៏ទ្រង់រិទ្ធិ និងទ្រង់ចេស្ដា ។

## ២៥- ម្នាលបុត្រនៃធម៌អើយ!

ចូរកុំរើសអើងលើជនទុរគត ព្រោះយើងជាអ្នកនាំផ្លូវអោយដល់គេបើប្រមើលឃើញអ្នកស្ថិតនៅក្នុងសភាពអាក្រក់នេះ យើងនឹងធ្វើអោយអ្នកវិតត្តិវិលជារៀងរហូត ។

## ២៦- ម្នាលបុត្រនៃជីវិតអើយ!

ម្តេចក៏អ្នកបំភ្លេចទោសកំហុសខ្លួន ទៅជ្រៀតជ្រែកប្រាណជាមួយទោសកំហុសរបស់អ្នកដទៃ? អ្នកដែលប្រព្រឹត្តដូចនេះនឹងត្រូវទទួលទោសជាមិនខាន ។

## ២៧- ម្នាលបុត្រនៃមនុស្សអើយ!

ចូរកុំពោលពីបាបរបស់អ្នកដទៃ ក្នុងខណៈពេលអ្នកក៏ជាជនដែលមានបាប បើអ្នកល្មើសលើធម្មបញ្ញត្តិនេះ ទុក្ខទោសនឹងកើតមានដល់អ្នក ហើយមានយើងជាសាក្សី ។

## ២៨- ម្នាលបុត្រនៃធម៌អើយ!

ចូរអ្នកចាំអោយជាក់ថា អ្នកដែលប្រាប់គេអោយសាងអំពើល្អ តែខ្លួនបែរជាបង្កភាពទុច្ចរិត បុគ្គលនេះមិនបានពាក់ព័ន្ធជាមួយនឹងយើងទេ សូម្បីគេយកឈ្មោះយើងមកអះអាងក៏ដោយ ។

## ២៩- ម្នាលបុត្រនៃជីវិតអើយ!

ចូរកុំអោយអ្នកដទៃ ក្នុងករណីដែលអ្នកក៏មិនចង់អោយគេថា និងកុំនិយាយអ្វីហើយបែរមិនធ្វើ ។ នេះជាធម្មបញ្ញត្តិរបស់យើងដែលអ្នកត្រូវប្រកាន់ខ្ជាប់ ។

## ៣០- ម្នាលបុត្រនៃមនុស្សអើយ!

ចូរកុំបដិសេធចំពោះសាវ័ករបស់យើង ប្រសិនបើគេសំណូមពរអ្វីពីអ្នក ។ ព្រោះទឹកមុខរបស់គេក៏ដូចជាព្រះភក្ត្ររបស់យើងដែរ ។ ហេតុដូច្នេះ ចូររលះរលាំងកាលបើនៅពីមុខយើង ។

## ៣១- ម្នាលបុត្រនៃជីវិតអើយ!

ចូរនាំខ្លួនរបស់អ្នកទៅពិនិត្យអោយបានរាល់ថ្ងៃ មុនពេលគេកោះហៅអ្នកទៅទូទាត់បញ្ជី ព្រោះសេចក្តីស្លាប់មិនអាចប្រាប់ជាមុន

ឡើយ អាចចំពេលដែលអ្នកត្រូវគេកោះហៅទៅទូទាត់បញ្ជីពីការប្រព្រឹត្តរបស់អ្នក ។

## ៣២- ម្នាលបុត្រនៃភាពឧត្តមអើយ!

យើងបានបង្កើតអោយមានសេចក្តីស្លាប់ គឺជាអ្នកនាំសារនៃសេចក្តីសប្បាយមួយសំរាប់អ្នក ម្តេចក៏អ្នកទុក្ខសោក? យើងបានតាក់តែងភាពរុងរឿងឡើងមកដើម្បីស្រោចស្រប់ដល់រូបអ្នក ម្តេចក៏អ្នកបិទបាំងប្រាណទៅវិញ?

## ៣៣- ម្នាលបុត្រនៃធម៌អើយ!

យើងបានស្វាគមន៍អ្នក ដោយរស្មីដំណឹងដ៏សែនរីករាយ ចូរអ្នករីករាយចុះ! យើងបានកោះហៅអ្នកទៅកាន់ធម្មសាលា ចូរអ្នកស្នាក់នៅទីនោះទៅ ទើបអ្នកអាចរស់នៅដោយស្ងប់សុខជារៀងរហូតបាន ។

## ៣៤- ម្នាលបុត្រនៃធម៌អើយ!

វិញ្ញាណបរិសុទ្ធ បាននាំដំណឹងដ៏សែនបរិសុទ្ធមកដល់អ្នក ស្តីពីការមករួមរស់ជាមួយគ្នាវិញ ។ ហេតុម្តេចឡើយក៏អ្នកនៅតែទុក្ខ

សោក? វិញ្ញាណនៃអនុភាពបានអះអាងចំពោះអ្នកពីសាសនារបស់ព្រះជាម្ចាស់ ម្ដេចក៏មិនបិទបាំងខ្លួនទៅវិញ? ពន្លឺនៃព្រះភក្ដ្ររបស់ព្រះអង្គដឹកនាំអ្នក តើអ្នកអាចវង្វេងផ្លូវដោយរបៀបណា?

## ៣៥- ម្នាលបុត្រនៃមនុស្សអើយ!

ចូរកុំព្រួយលើកលែងតែអ្នកប្រាស់ចាកពីយើង និងកុំសប្បាយលើកលែងតែអ្នកកំពុងចូលជិត និងកំពុងត្រឡប់មករកយើង ។

## ៣៦- ម្នាលបុត្រនៃជីវិតអើយ!

ចូររីករាយក្នុងបីតិសោមនស្សនៃបេះដូងរបស់អ្នកទើបអ្នកអាចមានវាសនាបានជួបយើងនិងសំដែងនូវសោភ័ណភាពរបស់យើង។

## ៣៧- ម្នាលបុត្រនៃមនុស្សអើយ!

ចូរកុំដោះសំលៀកបំពាក់ដ៏ពិសិដ្ឋរបស់យើង ចេញពីខ្លួនរបស់អ្នក និងកុំធ្វើអោយបាត់បង់ភោគផលរបស់អ្នក ពីប្រភពទឹកដ៏មហាស្ចារ្យរបស់យើង ក្រែងលោអ្នកស្រេចគ្មានថ្ងៃបញ្ចប់ ។

## ៣៨- ម្នាលបុត្រនៃជីវិតអើយ!

ដើម្បីសេចក្តីស្រឡាញ់របស់យើង ចូរអ្នកដើរតាមក្រិត្យវិន័យរបស់យើងនិងប្រសិនបើអ្នកចង់ស្វែងរកសេចក្តីរីករាយរបស់យើង ចូរបដិសេធនូវអ្វីដែលខ្លួនអ្នកប្រាថ្នា ។

## ៣៩- ម្នាលបុត្រនៃមនុស្សអើយ

ចូរកុំប្រហែសចំពោះក្រិត្យបញ្ញត្តិរបស់យើង បើអ្នកស្រឡាញ់សោភ័ណភាពរបស់យើង និងកុំបំភ្លេចបរមឱវាទរបស់យើង ប្រសិនបើអ្នកចង់សំរេចដល់បរមសុខរបស់យើង ។

## ៤០- ម្នាលបុត្រនៃមនុស្សអើយ!

ទោះបីជាអ្នកហោះហើរលើអាកាស និងឆ្លងកាត់វេហាយ៉ាងលឿនរហ័សក៏ដោយក៏អ្នករកសេចក្តីសុខគ្មានដែរ ក្រៅពីប្រតិបត្តិតាមធម្មបញ្ញត្តិរបស់យើង និងសំអោនកាយពីមុខយើង ។

## ៤១- ម្នាលបុត្រនៃមនុស្សអើយ!

ចូរពង្រីកបុព្វហេតុរបស់យើង ទើបយើងអាចបង្ហាញភាពអាថ៌កំបាំងនៃបាដិហារ្យរបស់យើង និងបំភ្លឺអនន្តរស្មីបានដល់អ្នក ។

## ៤២- ម្នាលបុត្រនៃមនុស្សអើយ!

ចូរលំអោនកាយពីមុខយើង ទើបយើងអាចមកប្រាស្រ័យទាក់ទងជាមួយអ្នកបាន ។ ចូរក្រោកឡើងដើម្បីជោគជ័យនៃបុព្វហេតុសាសនារបស់យើង និងនៅក្នុងខណៈពេលដែលអ្នកស្នាក់នៅលើលោកសន្និវាសនេះ អ្នកអាចសំរេចដល់នូវជ័យជំនះ។

## ៤៣- ម្នាលបុត្រនៃជីវិតអើយ!

នៅលើលោកសន្និវាសនេះអ្នកត្រូវតែរំលឹកដល់យើង ទើបក្នុងឋានសួគ៌យើងអាចគត់ចំណាំអ្នកបាន។ ដូច្នេះទើបអ្នកនិងយើងបានស្ងប់ដួងចិត្ត ។

## ៤៤- ម្នាលបុត្រនៃបល្ល័ង្កអើយ!

ការបានឮរបស់អ្នក គឺជាសវនាការរបស់យើង ចូរអ្នកស្តាប់តាមសវនាការនេះចុះ ក្រសែចក្ខុរបស់អ្នកគឺជាចក្សុបថរបស់យើង ចូរអ្នកសំលឹងតាមចក្សុបថនេះចុះ ដើម្បីអោយវិញ្ញាណរបស់អ្នកអាចអះអាងពីភាពបរិសុទ្ធដ៏ប្រសើររបស់យើង ហើយយើងអាចធ្វើជាសក្ខីភាពដល់ឋានៈដ៏ឧត្តមរបស់អ្នក ។

## ៨៥- ម្នាលបុត្រនៃជីវិតអើយ!

ចូរស្វែងរកការធ្វើពលិកម្ម ក្នុងនាមជាទុក្ករបុគ្គលរបស់យើង រីករាយតាមការពេញចិត្តរបស់យើង និងថ្លែងបដិការគុណនូវអ្វីដែលយើងបានកំណត់អោយដើម្បីអោយអ្នកអាចស្នាក់ជាមួយយើងក្រោមប្រាសាទនៃរាជសក្តានុភាព ខាងក្រោយបដិសរណដ្ឋាននៃភាពរុងរឿង ។

## ៨៦- ម្នាលបុត្រនៃមនុស្សអើយ!

ចូរពិចារណាមើលទៅតើអ្នកសុខចិត្តស្លាប់លើខ្នមកំសត់របស់អ្នក ឬបង្ហូរឈាមលើល្អងធូលី ឬក៏សុខចិត្តធ្វើជាទុក្ករបុគ្គល ក្នុងធម្មបថរបស់យើងដើម្បីសំដែងនូវក្រិត្យបញ្ញា និងបញ្ចាំងរស្មីរបស់យើងក្នុងស្ថានសួគ៌ដ៏ឧត្តមអោយលេចប្រត្យក្សឡើង? ចូរគិតសំគីអោយបានច្បាស់ណាសាវ័កសាវិកាអើយ ។

## ៨៧- ម្នាលបុត្រនៃមនុស្សអើយ!

ដោយសោភ័ណភាពរបស់យើងជាសាក្សីថា! ក្នុងក្រសែចក្ខុរបស់យើងនោះ ការជ្រលក់សរសៃអ្នកដោយលោហិតរបស់អ្នក

នោះ វាប្រសើរជាងការបង្កើតចក្រវាឡ និងពន្លឺនៃភពទាំងពីរទៅទៀត ។ ចូរព្យាយាមសំរេចនូវវត្ថុនេះណាសាវ័កសាវិកាអើយ!

## ៤៨- ម្នាលបុត្រនៃមនុស្សអើយ!

គ្រប់វត្ថុទាំងអស់គឺមានសញ្ញា ឯសញ្ញានៃសេចក្តីស្រឡាញ់គឺការអត់ធ្មត់នៅក្រោមក្រិត្យបញ្ញា និងស៊ូទ្រាំនៅក្រោមការសាកល្បងរបស់យើង ។

## ៤៩- ម្នាលបុត្រនៃមនុស្សអើយ!

អ្នកដែលស្រលាញ់ពិតនេះ ប្រាថ្នានូវការធ្វើពលិកម្ម បីដូចជាឧទ្ទាមម្នាក់ប្រាថ្នាការលើកលែងទោសនិងអ្នកមានបាបគ្រោះឥប្រាថ្នានូវក្តីករុណា ។

## ៥០- ម្នាលបុត្រនៃមនុស្សអើយ!

បើក្តីទុក្ខលំបាកមិនកើតមានដល់អ្នក ក្នុងធម្មបថរបស់យើងទេនោះ តើអ្នកអាចដើរតាមផ្លូវនៃអ្នក ដែលពេញចិត្តនឹងសេចក្តីរីករាយរបស់យើងបានដោយរបៀបណា? និងប្រសិនបើក្តីប្រាថ្នា

របស់អ្នកក្នុងការមកជួបយើង មិនបានទទួលការសាកល្បងអោយលំបាក តើអ្នកអាចសំរេចដល់ពន្លឺនៃសេចក្តីស្រលាញ់របស់អ្នកចំពោះសោភ័ណភាពរបស់យើងបានដូចម្តេច?

## ៥១- ម្នាលបុត្រនៃមនុស្សអើយ!

ទុក្ខសោករបស់យើង គឺជាអនន្តញ្ញាណរបស់យើង ផ្នែកខាងក្រៅជាភ្លើងនិងការចងពៀរ តែផ្នែកខាងក្នុងជាពន្លឺនិងមេត្តាធម៌។ ចូរប្រញាប់ទៅ ដើម្បីអោយអ្នកបានក្លាយជាអនន្តរស្មី និងអមរវិញ្ញាណ ។ នេះជាធម្មបញ្ញត្តិរបស់យើង ។

## ៥២- ម្នាលបុត្រនៃមនុស្សអើយ!

បើការលើកដំកើងកើតមានចំពោះអ្នក ចូរកុំត្រេកអរ! និងប្រសិនបើការបន្ទាបបន្ថោកអន្ទោលមកដល់អ្នក ចូរកុំព្រួយ!ព្រោះវត្ថុទាំងពីរនេះនឹងរលប់ទៅមិនស្ថិតនៅរហូតឡើយ ។

## ៥៣- ម្នាលបុត្រនៃជីវិតអើយ!

បើភាពក្រក្រីគ្របដណ្តប់លើរូបអ្នកចូរកុំទុក្ខសោក! ព្រោះថ្ងៃណាមួយនោះព្រះជាម្ចាស់នៃសម្បត្តិនឹងមកដល់អ្នក កុំខ្លាចការ

បន្ទាបបន្ថោក ព្រោះពេលខាងមុខភាពរុងរឿងនឹងមកនិត្យនៅជាមួយអ្នក ។

## ៥៤- ម្នាលបុត្រនៃជីវិតអើយ!

ប្រសិនបើបេះដូងរបស់អ្នកស្វែងរកអាណាចក្រអនន្ត និងជីវិតអមតៈ ចូរមកលះបង់អោយឆ្ងាយពីអធិបតេយ្យភាពមិនទៀងទាត់នេះចោលទៅ ។

## ៥៥- ម្នាលបុត្រនៃមនុស្សអើយ!

ចូរកុំអំពល់ប្រាណជាមួយពិភពសន្និវាសនេះ ព្រោះយើងបានសាកល្បងមាសដោយភ្លើង សាកល្បងសាវ័ក-សាវិការបស់យើងដោយមាស ។

## ៥៦- ម្នាលបុត្រនៃមនុស្សអើយ!

អ្នកប្រាថ្នាចង់បានមាស តែយើងប្រាថ្នាអោយអ្នករំដោះខ្លួនឱ្យបានឆ្ងាយពីវា ។ អ្នកគិតថាគ្រាណាដែលអ្នកមានមាស គ្រានោះឯងគឺគ្រាដែលអ្នកមាន តែយើងយល់ថាគ្រាណាដែលអ្នកមាននោះ គឺគ្រាដែលអ្នកជ្រះស្អាតពីវា ។ ពិតប្រាកដណាស់! នេះជា

បញ្ញាញាណរបស់យើង នោះគឺជាការស្រមៃរបស់អ្នក តើផ្លូវរបស់យើងនិងអ្នកអាចប្រព្រឹត្តទៅជាមួយគ្នាដោយរបៀបណា ។

## ៥៧- ម្នាលបុត្រនៃមនុស្សអើយ!

ចូរចែកអំណោយទ្រព្យរបស់យើង ដល់ជនទុរគតរបស់យើង ទើបក្នុងស្ថានសួគ៌ អ្នកអាចទទួលយកពីឃ្លាំងទ្រព្យនៃវិរោចនភាពដ៏មិនចេះរលត់ និងពីរតនាគារនៃភាពរុងរឿង ដែលមិនចេះសាបសូន្យ។ ជាមួយគ្នានេះជីវិតរបស់យើងបានធ្វើសក្ខីថា:វត្ថុដ៏ប្រសើរជាងនេះទៅទៀតនោះគឺការបូជាដួងវិញ្ញាណរបស់អ្នក បើអ្នកបានឃើញតាមចក្សុបថរបស់យើង ។

## ៥៨- ម្នាលបុត្រនៃមនុស្សអើយ!

វិហារនៃជីវិតរបស់អ្នកគឺជារាជបល្ល័ង្ករបស់យើងចូរជំរះអោយស្អាតពីវត្ថុទាំងឡាយ ទើបយើងអាចចុះមកស្ថាបនាប្រោះព្រំនិងប្រថាប់នៅទីនោះ ។

## ៥៩- ម្នាលបុត្រនៃជីវិតអើយ!

បេះដូងរបស់អ្នកគឺជារាជតំណាក់របស់យើង ចូរអ្នកលាងជំរះអោយបរិសុទ្ធដើម្បីការចុះមកប្រថាប់នៅរបស់យើង។ ដួងវិញ្ញាណរបស់អ្នកជាទីសំដែងរូបយើង ចូរអ្នកតាក់តែងអោយប្រណិតដើម្បីការប្រាកដឡើងមកសំដែងរបស់យើង ។

## ៦០- ម្នាលបុត្រនៃមនុស្សអើយ!

ចូរដាក់ហត្ថារបស់អ្នកលើក្រសោមទ្រូងរបស់យើង ទើបយើងអាចប្រសិទ្ធី និងប្រោះព្រំរស្មីបានដល់អ្នក ។

## ៦១- ម្នាលបុត្រនៃមនុស្សអើយ!

ចូរឡើងមកកាន់ស្ថានសួគ៌របស់យើង ទើបអ្នកអាចទទួលនូវសេចក្តីរីករាយនៃការវិលមកជួបជុំគ្នាវិញ និងក្រេបទឹកអម្រឹតពីពែងនៃភាពរុងរឿងអមតៈ ។

## ៦២- ម្នាលបុត្រនៃមនុស្សអើយ!

ច្រើនថ្ងៃបានកន្លងផុតទៅ អ្នកកំពុងនៅរវល់ប្រាណជាមួយក្តីស្រមើស្រមៃ និងចិន្តនាការដ៏រវើរវាយរបស់អ្នក។ តើអ្នកនឹងលង់

លក់លើខ្មុកំសត់របស់អ្នកដល់ណាទៀត? ចូរលើកសិរសារបស់អ្នកពីការលង់លក់នេះមក ព្រោះដួងរស្មីបានរះឡើងមកដល់កំពូលនភាហើយ ក្រែងលោអាចសាចរស្មីសោភ័ណភាព បានដល់អ្នក។

## ៦៣– ម្នាលបុត្រនៃមនុស្សអើយ!

ដួងពន្លឺនៃសច្ចធម៌បានបញ្ចាំងរស្មីពីនភា នៃអមរបពិតដល់អ្នក និងដួងវិញ្ញាណនៃបញ្ញា បានផ្តល់ដង្ហើមដល់សរសៃបេះដូងរបស់អ្នកហើយ ។ ដូច្នេះ ចូរអ្នករំដោះខ្លួនអោយរួចពីស្បៃនៃសេចក្តីស្រមើស្រមៃនោះមក ហើយចូលទៅកាន់អារាមបរិសុទ្ធរបស់យើង ទើបអ្នកមានតំលៃសក្តិសមជាមួយជីវិតអមតៈ និងមានវាសនាបានជួបយើង។ ដូច្នេះហើយទើបសេចក្តីស្លាប់មិនអាចកើតមានចំពោះអ្នក រួមទាំងក្តីទុក្ខនិងការព្រួយកង្វល់ទាំងពួង ។

## ៦៤– ម្នាលបុត្រនៃមនុស្សអើយ!

អនន្តរភាពរបស់យើងគឺការបង្កើតរបស់យើង យើងបានបង្កើតវាឡើងសំរាប់អ្នកលំអសិរសារបស់អ្នកដោយគ្រឿងប្រដាប់នេះចុះ។ ការបង្រួបបង្រួមរបស់យើង គឺជាសិប្បកម្មរបស់យើង

យើងបានតាក់តែងវាឡើងសំរាប់អ្នក ចូរអ្នកដណ្តប់ប្រាណដោយសំលៀកបំពាក់នេះចុះដើម្បីអោយអ្នកអាចសំដែងភាវៈអមតៈរបស់យើងជានិច្ចនិរន្តរបាន ។

## ៦៥- ម្នាលបុត្រនៃមនុស្សអើយ!

សក្តានុភាពរបស់យើងជាអំណោយសំរាប់អ្នក ឯភាពរុងរឿងរបស់យើង គឺជាសញ្ញានៃក្តីករុណារបស់យើងចំពោះអ្នក វត្ថុដ៏សាកសមនឹងរូបយើងនេះ មិនមាននរណាយល់និងពិពណ៌នាបានឡើយ ។ ពិតប្រាកដណាស់! យើងបានរក្សាវាទុកក្នុងឃ្លាំងអាថ៌កំបាំង និងក្នុងរតនាគារនៃអធិបញ្ញារបស់យើង ទុកជានិមិត្តរូបនៃសេចក្តីប្រតិព័ទ្ធ ដល់សាវ័កសាវិការបស់យើង និងជាក្តីមេត្តាដល់មនុស្សលោកទាំងឡាយរបស់យើង ។

## ៦៦- ម្នាលកុមារនៃខ្លឹមសារអនន្តអើយ!

អ្នកនឹងត្រូវបិទបាំងពីការស្រលាញ់រូបយើង ឯបេះដូងរបស់អ្នកនឹងត្រូវញ័រចំប្រប់ញាប់ញ័រ ពេលដែលលឺគេពោលពីរូបយើង។

ព្រោះសតិបញ្ញារបស់អ្នកមិនអាចយល់និងបេះដូងរបស់អ្នកមិនបាន ជិតជាប់រូបយើង ។

## ៦៧– ម្នាលបុត្រនៃមនុស្សអើយ!

ដោយវិញ្ញាណនិងក្តីមេត្តា ដោយក្តីករុណានិងសោភ័ណភាពរបស់យើង យើងធ្វើជាសក្ខីភាពថា:គ្រប់វត្ថុទាំងឡាយដែលយើងបានសំដែងដល់អ្នកដោយអណ្តាតដ៏ទ្រង់រិទ្ធិ និងចារឹកដោយស្លាបប៉ាកកានៃរិទ្ធានុភាពនោះ គឺបានអនុលោមទៅតាមសមត្ថភាព និងការយល់ដឹងរបស់អ្នក មិនមែនតាមសភាវៈ និងបទសំនៀងរបស់យើងឡើយ ។

## ៦៨– ម្នាលបុត្រនៃមនុស្សអើយ!

តើអ្នកដឹងទេថា ហេតុអ្វីបានជាយើងបង្កើតរូបអ្នកឡើងមកពីធូលីដូចគ្នា? គឺដើម្បីមិនអោយពួកអ្នកវាយឫកដាក់គ្នា។ ចូរអ្នកសញ្ជឹងគិតអោយបានល្អិតល្អន់ និងគ្រប់វេលានូវអ្វីដែលរូបអ្នកត្រូវបានបង្កើតឡើងមក ។ ដោយសារយើងបង្កើតរូបអ្នក អ្នកដែលត្រូវប្រព្រឹត្តចំពោះគ្នាបីដូចជាបេះដូងតែមួយ ដើរដោយបាទាដូច

គ្នា បរិភោគដោយមាត់ដូចគ្នា រស់នៅលើលោកដូចគ្នា និងដើម្បីអោយគ្រប់ទង្វើនិងអំពើសកម្មភាពរបស់អ្នកគ្រប់សញ្ញា ឯកភាពនិងខ្លឹមសារនៃការមិនជំពាក់ ដែលកើតមកពីដួងចិត្តរបស់អ្នកនោះអាចលេចប្រត្យក្សឡើងបាន។ ឱជន្នានុជននៃពន្លឺអើយនេះជាពាក្យប្រៀនប្រដៅរបស់យើង ចូរយកចិត្តទុកដាក់ប្រតិបត្តិតាម ដើម្បីអោយអ្នកបានទទួលនូវផល្លាបរិសុទ្ធពីព្រឹក្សា នៃភាពរុងរឿងដ៏មហស្ចារ្យ ។

## ៦៩– ម្នាលបុត្រនៃធម៌អើយ!

អ្នកជាឃ្លាំងទ្រព្យរបស់យើង ព្រោះនៅក្នុងខ្លួនរបស់អ្នកយើងបានរក្សានូវគុជនិងត្បូងនៃវិជ្ជារបស់យើង ។ ចូរអ្នកការពារឱ្យបានរួចផុតពីជនចំឡែកក្នុងក្រុមនៃសាវ័កសាវិការបស់យើង និងជនអធម៌ទាំងឡាយក្នុងចំណោមមនុស្សរបស់យើង ។

## ៧០– ម្នាលបុត្រនៃអ្នកស្មោះត្រង់អើយ!

ចូរអ្នកចាត់ទុកថា យើងបានបក់ផាត់នូវសុគន្ធរសនៃភាពបរិសុទ្ធរបស់យើងមកដល់អ្នក បានសំដែងព្រះវចនៈយ៉ាងច្រើនអនេក

បានផ្តល់ករុណារបស់យើងច្រើនយ៉ាងសំបូរណ៍ដល់រូបអ្នក និង ប្រាថ្នាអោយអ្នក នូវវត្ថុដែលយើងបានប្រាថ្នាទុកសំរាប់ខ្លួនយើង។ ដូច្នេះ ចូរអ្នកសំដែងនូវបដិការគុណចំពោះយើង និងពេញចិត្ត នឹងសេចក្តីជ្រះថ្លារបស់យើង ។

## ៧១- ម្នាលបុត្រនៃមនុស្សអើយ!

ចូរចារឹកគ្រប់វត្ថុទាំងឡាយដែលយើងបានសំដែងដល់អ្នកលើ ថ្ពាលដួងចិត្តរបស់អ្នក ដោយទឹកប៊ិចនៃពន្លឺ បើអ្នកគ្មានអនុភាព ចូរត្របាញ់ដួងចិត្តរបស់អ្នកអោយក្លាយជាទឹកប៊ិច ។ បើប្រការនេះ ហើយនៅតែមិនបានសំរេច ចូរចារឹកដោយទឹកប៊ិចក្រហម ។ ពិត ប្រាកដណាស់ វត្ថុនេះវាផ្អែមលើសអ្វីៗទាំងអស់សំរាប់យើង ហើយពន្លឺនេះនឹងចិតថេរជានិរន្តរ ។

# ព្រះធម៌អាថ៌កំបាំង

## *ភាគ២ ... ពីភាសាពៃក្យ*

ក្នុងនាមជាព្រះជាម្ចាស់ ព្រះអង្គទ្រង់រិទ្ធានុភាព

### ១- ម្នាលប្រជាពលលោកអ្នកដែលមានបញ្ញាអាចយល់និងមានត្រចៀកអាចស្តាប់បាន

ព្រះសូរសៀងដំបូងរបស់ព្រះគុណម្ចាស់នេះគឺ:ឱ!បក្សី*ណៃធីងហ្គេល*ដ៏អាថ៌កំបាំងអើយ!ចូរកុំអាស្រ័យនៅទីណាក្រៅពីសួនកុឡាបនៃធម៌ ឱអ្នកនាំសារនៃ*សូឡូម៉ុន*ដ៏ជាទីស្រលាញ់អើយ! ចូរកុំស្នាក់នៅទីណាក្រៅពីក្នុង *ឈីពបា* របស់ *សមគ្គិទេព្វ* ឱបក្សី*ហ្វិនីជ*ដ៏អមតៈអើយ! ចូរកុំជ្រកទីណាក្រៅពីបពិតនៃសច្ចភាព ។ ទីនេះហើយជាលំនៅស្ថានរបស់អ្នក ចូរអ្នកហើរទៅកាន់អាណាចក្រនៃអនន្តភាពនេះចុះ ដោយស្លាបនៃវិញ្ញាណរបស់អ្នកហើយព្យាយាមសំរេចអោយដល់គោលដៅរបស់អ្នក ។

## ២– ម្នាលបុត្រនៃធម៌អើយ!

បក្សីស្វែងរកសំបុកវិហគ្គ *ណែធីងហ្គេល* ស្វែងរកស្នេហ៍ពីផ្កាកុឡាប ចំណែកឯបេះដូងរបស់មនុស្សទៅពេញចិត្តជាមួយធូលីមិនទៀងទាត់ ប្រាស់ឆ្ងាយពីទ្រនំអននន្តរបស់ខ្លួន លិចលង់ក្នុងអន្លង់នៃក្តីប្រមាទបណ្តាលអោយព្រាត់ពីភាពរុងរឿងនៃទិព្វស្ថាន។គួរឱ្យអាណោចនិងអនិច្ចាណាស់! គ្រាន់តែទឹកមួយទូកដៃ ពួកគេបានបែរមុខចេញពីមហាសមុទ្រដ៏ធំល្វឹងល្វើយរបស់ព្រះ ករុណាធិគុណម្ចាស់ និងស្ថិតនៅឆ្ងាយពីនភាដ៏ត្រកាលរបស់ព្រះអង្គ ។

## ៣– ម្នាលសំលាញ់ទាំងឡាយអើយ!

ក្នុងឧទ្យាននៃដួងចិត្តរបស់អ្នក ចូរកុំបណ្តុះអ្វីក្រៅពីកុឡាបនៃសេចក្តីស្រលាញ់ និងកុំបណ្តោយឱ្យបក្សីនៃក្តីប្រាថ្នាដ៏ជាទីប្រតិពទ្ធ័របូតរួចពីក្រសោមទ្រូងរបស់អ្នក ហើយចូររក្សាមេត្រីចិត្ត មិត្តភាពជាមួយអ្នកមានធម៌ និងជៀសវាងការចងចិត្តជាមួយជនអធម៌ទាំងពួង ។

## ៤– ម្នាលបុត្រនៃសេចក្តីយុត្តិធម៌អើយ!

តើអ្នកដែលស្រលាញ់ណាម្នាក់ អាចទៅក្រៅពីដែនដីនៃម្ចាស់ស្នេហ៍របស់ខ្លួន? និងអ្នកដែលស្វែងរកណាម្នាក់ទៅ អាចស្ងប់នូវជំរៅក្តីប្រាថ្នា? អ្នកដែលស្រឡាញ់ពិត ការបានជួបគឺជាជីវិតឯការព្រាត់ប្រាស់គឺក្តីមរណា។ទ្រូងរបស់គេត្រូវបាត់បង់នូវសេចក្តីអំណត់ បេះដូងប្រាសចាកនូវសេចក្តីសុខសាន្ត ។ ទោះបីជារាប់អសង្ខៃនៃជីវិតក៏គេហ៊ានប្តូរ អោយតែឆាប់បានទៅដល់ត្រើយស្ពាននៃម្ចាស់ស្នេហ៍ ។

## ៥– ម្នាលបុត្រនៃធូលីអើយ!

ពិតប្រាកដណាស់ដូចដែលយើងបានពោល ក្នុងបណ្តាមនុស្សទាំងអស់ អ្នកដែលធ្វេសប្រហែសបំផុត គឺអ្នកដែលចូលចិត្តឈ្លោះប្រកែកគ្មានខ្លឹមសារ ហើយស្វែងរកប្រៀបលើញាតិមិត្តបងប្អូនរបស់ខ្លួន ។ ហៃភាតរៈទាំងឡាយអើយ! ចូរអ្នកយកការប្រព្រឹត្តអោយប្រសើរបំផុត លើសការយកសំដីជាគ្រឿងលំអរបស់អ្នក ។

## ៦- ម្នាលបុត្រនៃលោកិយអើយ!

ពិតប្រាកដណាស់ ចូរអ្នកចាំទុកថាបេះដូងដែលមានសំណល់សេចក្តីច្រណែនសូម្បីតែបន្តិចបន្តួចនោះក៏មិនអាចទៅដល់អមរភព និងមិនអាចស្រូបយកសុគន្ធរសបរិសុទ្ធ ពីស្ថាននៃវិសុទ្ធភាពបានឡើយ ។

## ៧- ម្នាលបុត្រនៃក្តីស្រឡាញ់អើយ!

អ្នកនៅត្រឹមតែមួយជំហានប៉ុណ្ណោះ ពីវិរោចនស្ថាននិងព្រឹក្សានៃសេចក្តីស្រឡាញ់ ចូរអ្នកឈានមកហើយមួយជំណាក់ទៀតចូលទៅកាន់អមរស្ថាន និងប៉ាំរាំនៃអនន្តភាពហើយផ្ទៀងផ្ទាត់ស្តាប់នូវអ្វីដែលបានសំដែងដល់អ្នក ដោយស្លាបប៉ាកកានៃភាពរុងរឿង ។

## ៨- ម្នាលបុត្រនៃភាពរុងរឿងអើយ!

ចូរអ្នកប្រញាប់មកកាន់ផ្លូវនៃភាពបរិសុទ្ធ និងពិភពនៃការជួបជុំគ្នាជាមួយយើងហើយចូរជុសខាត់បេះដូងរបស់អ្នកដោយពន្លឺរស្មីនៃដួងវិញ្ញាណ និងរលះរលាំងចូលទៅកាន់ អារាមនៃព្រះគុណម្ចាស់ ។

## ៩- ម្នាលស្រមោលមិនទៀងទាត់អើយ!

ចូរអ្នកឆ្លងអោយផុតពីសំណាក់នៃក្តីមន្ទិល និងឆ្ពោះទៅកាន់ឧត្តមស្ថាននៃភាពជឿទុកចិត្ត ។ ចូរអ្នកបើកភ្នែកនៃសច្ចធម៌ទើបអ្នកអាចសំលឹងឃើញសោភ័ណភាពដ៏ត្រចះត្រចង់ ហើយឧទានឡើងថាៈ ព្រះអង្គទ្រង់វិសុទ្ធភាព និងប្រសើរអស់លើពួកមាកកជនទាំងពួង ។

## ១០- ម្នាលបុត្រនៃកិលេសអើយ!

ចូរអ្នកចាំទុកថាៈលោកិយចក្ខុមិនអាចសំលឹងឃើញសោភ័ណភាពទិព្វបានឡើយ ហើយបេះដូងដែលនិវាសជីវិតក៏មិនពេញចិត្តអ្វីក្រៅពីបុប្ផាដែលរុះរោយដែរ ។ ព្រោះវត្ថុដូចគ្នារមែងស្វែងរកវត្ថុដូចគ្នា ហើយពេញចិត្តក៏ចំពោះតែក្នុងវត្ថុប្រភេទដូចគ្នា ។

## ១១- ម្នាលបុត្រនៃធូលីអើយ!

ចូរបិទភ្នែករបស់អ្នកទើបអ្នកអាចសំលឹងឃើញសោភ័ណភាពរបស់យើង ចូរបិទត្រចៀករបស់អ្នក ទើបអ្នកអាចស្តាប់លឺសំលេងរបស់យើង ចូរសំអាតខ្លួនរបស់អ្នកពីចំណេះវិជ្ជាទាំងឡាយ ទើប

អ្នកអាចក្រេបយកចំណេះវិជ្ជារបស់យើង និងសំអិតសំអាងប្រាណរបស់អ្នកពីសម្បត្តិទាំងឡាយ ទើបអ្នកអាចទទួលយកអរិយទ្រព្យពីមហាសមុទ្រនៃសម្បត្តិអនន្តរបស់យើង ចូរបិទភ្នែករបស់អ្នកលើកលែងតែសោភ័ណភាពរបស់យើង ចូរបិទត្រចៀករបស់អ្នកលើកលែងតែសំលេងធម៌របស់យើង ។ ចូរសំអាតខ្លួនអ្នកពីចំណេះវិជ្ជាទាំងឡាយលើកលែងតែចំណេះវិជ្ជារបស់យើង។ដោយកែវភ្នែកដ៏ភ្លឺថ្លា បេះដូងបរិសុទ្ធ និងត្រចៀកទ្រឹងស្តាប់ អ្នកអាចចូលដល់អារាមបរិសុទ្ធរបស់យើង ។

## ១២- ម្នាលអ្នកដែលមានចក្ខុពីរអើយ!

ចូរបិទភ្នែកម្ខាង និងបើកភ្នែកម្ខាង បិទភ្នែកម្ខាងដែលសំលឹងទៅកាន់ពិភពលោកនិងសំភារៈខាងលោកីយ៍ ហើយចូរបើកភ្នែកម្ខាងទៀត ដែលសំលឹងទៅកាន់សោភ័ណភាពបរិសុទ្ធ របស់ព្រះគុណម្ចាស់ ។

## ១៣- ម្នាលអនុជនទាំងឡាយអើយ!

យើងខ្លាចតែរូបអ្នក ត្រូវព្រាត់ពីសំលេងបក្សីនៃស្ថានសួគ៌លិចលង់បាត់ទៅនៅក្នុងស្រមោលអន្ធកាល។ រូបកាយបានក្លាយជាទឹកនិងដី ទាំងមិនទាន់បានសំលឹងឃើញសំរស់កុលាបសួគ៌ផង។

## ១៤- ម្នាលសំលាញ់អើយ!

ចូរកុំបោះបង់សោភ័ណភាពអនន្តទៅលង់នឹងសំរស់មិនឋិតថេរ និងកុំដាក់ចិត្តរបស់អ្នកប្រតិព័ទ្ធទៅលើភពធូលី ដែលមិនទៀងទាត់នេះ ។

## ១៥- ម្នាលបុត្រនៃធម៌អើយ!

ពេលវេលាបានមកដល់ហើយ នៅពេលដែលបក្សី *ណៃធីងហ្គេល*នៃភាពបរិសុទ្ធ បញ្ឈប់ការលាតត្រដាងនូវភាពអាថ៌កំបាំងរូបអ្នកទាំងអស់គ្នានឹងត្រូវឃ្លាតពីភ្លេងទិព្វនិងព្រាត់ពីសំលេងសួគ៌។

## ១៦- ម្នាលខ្លឹមសារនៃក្តីប្រមាទអើយ!

ព្រះធម៌ដ៏ច្រើនអនេក បានបន្លឺឡើងក្នុងសុន្ទរកថាមួយ និងភាពអាថ៌កំបាំងដ៏ច្រើនឥតគណនា បានបញ្ចេញអោយដឹងក្នុងបទភ្លេងតែមួយ ។ តែគួរអោយអនិច្ចា!គ្មានត្រចៀកណាស្តាប់និងបេះដូងណាអាចយល់ ។

## ១៧- ម្នាលសំលាញ់ទាំងឡាយអើយ!

ក្លោងទ្វារឆ្ពោះទៅកាន់ស្ថានសួគ៌ស្ថិតនៅជាចំហ និងនិវេសនដ្ឋាននៃម្ចាស់ជីវិតត្រូវជិតដាមលំអដោយលោហិតនៃអ្នកដែលភក្តី។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏មានតែចំនួនដ៏តិចតួចប៉ុណ្ណោះដែលមិនបានព្រាត់ពីអមរបុរី និងសូម្បីក្នុងចំណោមដ៏តិចតួចនោះក៏មានមនុស្សមិនប៉ុន្មាននាក់ដែរ ដែលឃើញមានបេះដូងបរិសុទ្ធ និងដួងចិត្តជ្រះថ្លា ។

## ១៨- ម្នាលពពួកទេព្តានាស្ថានសួគ៌អើយ!

ចូរអ្នកប្រកាសដល់សាធុជនទាំងឡាយថា: នៅឯវិមានបរិសុទ្ធនាស្ថានសួគ៌ មានសួនឧទ្យានថ្មីមួយបានលេចប្រត្យក្សឡើងមួល

មីរនិងពោរពេញទៅដោយពពួកទេព្តា ទេពអប្សរ ទេពនិករ ទេពកញ្ញាក្នុងស្ថានសួគ៌ ។ ដូច្នេះ ចូរអ្នកព្យាយាមចូលអោយដល់ឧទ្យាននេះ អ្នកនឹងបានជ្រួតជ្រាបនូវភាពអាថ៌កំបាំងពីបុរ្វាទិព្វ និងបានដឹងនូវការសំងាត់ និងអច្ឆរិយគតិពីផល្លាសួគ៌នៃឧទ្យាននេះ ។ ពិតប្រាកដណាស់អ្នកដែលបានចូលទៅក្នុងឧទ្យាននេះនឹងបានស្រាកស្រាន្តអារម្មណ៍ ។

## ១៩- ឱសំឡាញ់ទាំងឡាយអើយ!

តើអ្នកភ្លេចព្រឹកព្រាងដ៏ត្រកាល នាពេលដែលអ្នកមកជួបជុំជាមួយយើង ក្នុងបរិយាកាសបរិសុទ្ធនិងប្រកបដោយពរសព្ទសាធុការក្រោមម្លប់នៃជីវិត ក្នុងស្ថានសួគ៌ដ៏រុងរឿងនោះហើយឬ?ពេលនោះអ្នកបានស្តាប់យ៉ាងរំជួលចិត្ត គ្រាដែលយើងបានពោលដល់ព្រះធម៌ទាំងបីនេះថា: ឱសំឡាញ់អើយ ចូរកុំប្រកាន់យកគំនិតរបស់ខ្លួនថាគ្រាន់បើជាងគំនិតរបស់យើង កុំប្រាថ្នាអ្វីដែលយើងមិនបំណងឱ្យនិងកុំចូលមកជិតយើងទាំងបេះដូងនិរាសជីវិត ព្រមទាំងប្រឡាក់ប្រឡូសដោយកិលេសតណ្ហា ។ ពិតណាស់ បើអ្នកបានដុសខាត់

ចិត្តវិញ្ញាណរបស់អ្នកអោយបរិសុទ្ធនោះ អ្នកនឹងនឹកឃើញដល់ទីកន្លែង និងបរិយាកាសទាំងនោះ ហើយព្រមទាំងសច្ចធម៌ដែលចេញពីឱកាសរបស់យើង អាចកើតជាទីប្រត្យក្សដល់អ្នកគ្រប់គ្នាជាមិនខាន ។

## ២០-ម្នាលអ្នកដែលកំពុងលង់លក់ក្នុងខ្នងនៃក្តីប្រមាទ!

អាយុក្ខ័យចេះតែរំកិលទៅ ឯជីវិតដ៏ជាទីស្រឡាញ់របស់អ្នកក៏ជិតទៅដល់ទីបំផុតហើយ ។ សូម្បីយ៉ាងនេះក៏ដោយ ក៏ពុំមានខ្យល់បរិសុទ្ធអ្វីបន្តិចបន្តួចបក់មកដល់ទិព្វវិមានរបស់យើងដែរ និងទោះបីជាអ្នកត្រូវលិចលង់ក្នុងសមុទ្រអន្ធកាល ក៏អណ្តាតរបស់អ្នកនៅតែអះអាងថា អ្នកមានសទ្ធាក្នុងព្រះជាម្ចាស់ មនុស្សដែលយើងទោមនស្ស អ្នកបែរជាស្រឡាញ់ ឯទមិទ្បរបស់យើងវិញ អ្នកបែរយកជាមិត្ត ប៉ុណ្ណឹងហើយអ្នកនៅត្រាច់ចរទន្ទ្រាន លើធរណីយ៉ាងង៉បងុល ប្រកបដោយកិលេសដោរជន់ប្រាណ ទាំងមិនដឹងថាធរណីនិងសត្វវត្ថុនៅក្នុងលោកនេះខ្ពើមរអើមអ្នកប៉ុណ្ណា។ បើសិន

ជាអ្នកគ្រាន់តែក្រឡេកមើល នោះអ្នកនឹងប្រាកដក្នុងចិត្តថាការទុក្ខសោកគ្រាន់ជាងក្តីសប្បាយ និងមរណៈ ប្រសើរជាងជីវិតនេះ ។

## ២១- ម្នាលចលនរូបអើយ!

យើងប្រាថ្នាប្រាស្រ័យទាក់ទងជាមួយអ្នក តែអ្នកគ្មានស្វាមីភក្តិចំពោះយើង ដាវអនារ្យធម៌របស់អ្នកបានផ្តួលរំលំព្រឹក្សានៃសេចក្តីសង្ឃឹមរបស់អ្នក ។ រាល់គ្រាដែលយើងបានចូលមកជិតអ្នក អ្នកជំលៀសប្រាណឆ្ងាយពីយើង។ ភាពរុងរឿងដ៏អមតៈដែលយើងបានជ្រើសទុកអោយអ្នក តែអ្នកបែរជាជ្រើសយកភាពអប្បយសមកដាក់ខ្លួនទៅវិញ។ ទាន់ពេលវេលានៅមាន ចូរអ្នកវិលត្រឡប់មកវិញ ដើម្បីកុំអោយឱកាសដ៏ប្រពៃនេះបាត់បង់ ។

## ២២- ម្នាលបុត្រនៃក្តីកិលេសអើយ!

ពពួកប្រាជ្ញបណ្ឌិត បានព្យាយាមរាប់សិបឆ្នាំនៅតែមិនបានចូលមកដល់ទិព្វស្ថានរបស់ព្រះជាម្ចាស់ និងចំណាយពេលរាប់ជីវិតរបស់ពួកគេ ដើម្បីស្វែងរកព្រះអង្គ នៅតែមិនបានសំលឹងឃើញ

សោភ័ណភាពនៃព្រះភក្ត្ររបស់ព្រះអង្គ ។ តែចំណែករូបអ្នកបាន សំរេចដល់ដោយមិនបាច់បញ្ចេញកំលាំងសូម្បីបន្តិចបន្តួច និងបាន ជួបនូវវត្ថុដ៏ជាទីប្រាថ្នាដោយមិនបាច់ស្រាវជ្រាវ។ ទោះបីយ៉ាងនេះ ក៏ដោយ ក៏អ្នកនៅតែលិចលង់ជាប់ក្នុងអន្លង់នៃអនត្តារបស់អ្នក ។ បណ្តាលអោយកែវភ្នែករបស់អ្នកត្រូវបិទបាំង មើលមិនឃើញ សោភ័ណភាពរបស់ព្រះជាម្ចាស់ និងហត្ថាមិនបានប៉ះជាយស្បៃ របស់ព្រះអង្គ។ ឱអ្នកដែលមានចក្ខុអើយ ចូរអ្នកខំប្រឹងបើកសំលឹង មើល គប្បីកុំមានពីភាល់និងមន្ទិលអ្វីឡើយ ។

## ២៣- ម្នាលពពួកទេពនាបុរីដ៏ប្រតិព័ទ្ធអើយ!

ព្យុះមច្ចុរាជបានបក់បោកទៅលើប្រទីបអមតៈ និងសោភ័ណ ភាពរបស់ទេវទូត ត្រូវដណ្តប់ដោយធូលីងងឹត។ បរមរាជាដ៏ជាទី ប្រតិព័ទ្ធត្រូវប្រទូស្តរាយដោយទមិឡគ្មានមេត្តា ឯបក្សីបរិសុទ្ធត្រូវ ជាប់ក្នុងក្រញ៉ាំចចកកំណាច។ ពពួកទេព្តានិងអប្សរដែលអាស្រ័យ នៅក្នុងព្រះប្រាសាទនៃភាពរុងរឿង ទ្រង់សោកពិលាប។ តែអ្នក

ត្រឡប់ជាយល់ថាខ្លួនអ្នកជាកល្យាណមិត្ត ។ ម្តេចក៏គំនិតរបស់អ្នក រវើរវាយឥតប្រយោជន៍អ្វីម៉្លេះ!

## ២៤- ម្នាលអ្នកដែលល្ងង់តែយល់ថាខ្លួនឆ្លាតអើយ!

ហេតុអ្វីក៏អ្នកពាក់អាក្ការៈក្រៅ នៃអ្នកគង្វាលសត្វរបស់យើង ក្នុងគ្រាដែលដួងចិត្តរបស់អ្នកជាសុនខព្រៃ រងចាំក្រញិពពួកសត្វ របស់យើង ។ រូបអ្នកហាក់បីដូចជាដួងតារារះមុនពេលព្រះសុរិយា បញ្ចេញរស្មី សូម្បីមើលទៅរុងរឿងថ្លាថ្លៃ គង់នាំអ្នកដែលស្វែងរក អមរបុរីរបស់យើង វង្វេងផ្លូវទៅកាន់មហន្តរាយដែរ ។

## ២៥- ម្នាលបុត្រដែលមើលទៅស្រស់ថ្លា តែក្នុងចិត្តខ្វក់ខ្មៅ!

អ្នកបីដូចជាទឹកដ៏ថ្លាតែមានពិសខាងក្រៅមើលទៅបរិសុទ្ធពិត តែពេលត្រូវពិសោធដោយអ្នកវិភាគពីស្ថានសួគ៌ ។ សូម្បីតែមួយ ដំណក់របស់អ្នកក៏មិនអាចទទួលបានដែរ ។ ដូចកាំរស្មីព្រះអាទិត្យ ចាំងជះទៅលើធូលីនិងកញ្ចក់ តែពន្លឺដែលចាំងត្រឡប់មកវិញខុស គ្នាដូចមេឃនិងដី និងមានភាពផ្សេងគ្នាច្រើនក្រៃរកវាស់មិនបាន។

## ២៦- ម្នាលសំលាញ់នៃឱវាទអើយ!

ចូរអ្នកសញ្ជឹងគិតមើលបន្តិចទៅ តើអ្នកធ្លាប់ដែលបានលីមិត្ត ហើយនិងសត្រូវ គួរអាស្រ័យនៅក្នុងបេះដូងតែមួយបានដែរឬទេ? ដូច្នេះចូរអ្នកលះបង់សត្រូវ ដើម្បីអោយមិត្តទៅអាស្រ័យលំនៅដ្ឋានរបស់ខ្លួនគេ ។

## ២៧- ម្នាលបុត្រនៃធូលីអើយ!

គ្រប់វត្ថុទាំងឡាយក្នុងស្ថានសួគ៌ និងលើផែនដីយើង យើងបានកំណត់ឡើងសំរាប់អ្នក លើកលែងតែបេះដូងរបស់មនុស្ស យើងបានកសាងឡើងជាអាសនៈ ទុកសំរាប់បារមីនិងភាពរុងរឿងរបស់យើង ។ ប៉ុន្តែរូបអ្នកបែរជាផ្តល់ទៅអោយអ្នកដទៃទើបរាល់គ្រាដែលបារមីរបស់យើងចុះមកស្ថិតក្នុងលំនៅស្ថាន ឃើញមានចំនៃទ្បែកនៅទីនោះរួចទៅហើយ ។ បាត់បង់ទីអាស្រ័យគេក៏រូតរះឃ្លាតខ្ចីឡើងមកកាន់ស្ថានសួគ៌វិញ ។ ទោះបីយ៉ាងនេះក៏ដោយ ក៏យើងនៅលាក់ការសំងាត់របស់អ្នក ដោយមិនចង់អោយអ្នកអាប់អន់អាត្មា ។

## ២៨-    ម្នាលខ្ទឹមសារនៃសេចក្តីប្រាថ្នាអើយ!

រៀងរាល់ពេលអរុណោភាស យើងបានចាកចេញពីស្ថានសួគ៌ មកកាន់លំនៅស្ថានរបស់អ្នក ឃើញអ្នកកំពុងលង់លក់នៅលើខ្នើយ យ៉ាងសប្បាយជាមួយនឹងអ្នកដទៃពេលនោះយើងក៏ឃ្លាតខ្ញីប្រញាប់ ត្រឡប់មកវិញមួយប៉ព្រិច ទាំងមិនស្រដីប្រាប់ពពួកទេព្តាទាំងពួង។

## ២៩-    ម្នាលបុត្រនៃសេចក្តីសប្បុរសអើយ!

យើងបាននិម្មិតរូបអ្នកឡើងពីមាតិកាដ៏បរិសុទ្ធដោយមហិទ្ធិរិទ្ធ នៃបញ្ញារបស់យើង និងបានត្រៀមទុកគ្រប់វត្ថុទាំងឡាយសំរាប់ការហ្វឹកហ្វឺនរបស់អ្នក ។ ហើយមុនពេលរូបអ្នកសម្តពពីគភ៌មាតាមក យើងបានកំណត់ជាមុននូវប្រភពខីរជាតិមួយគួរសំរាប់អ្នក ភ្នែកសំរាប់មើលថែទាំ និងបេះដូងសំរាប់ស្រឡាញ់រូបអ្នក ។ ក្រៅពីសេចក្តីសប្បុរសទាំងនេះ យើងបានថែរក្សារូបអ្នកក្រោមម្លប់ នៃសេចក្តីករុណានិងការពារឃុំគ្រងរូបអ្នក ដោយក្តីសណ្តោសមេត្តារបស់យើង។ ចេតនារបស់យើងក្នុងបច្ច័យទាំងអស់នេះគឺដើម្បីឱ្យអ្នកបានមកដល់វិជិតរាជ្យដ៏រុងរឿង និងមានកុសលផលបុណ្យបាន

ទទួលសព្ទសាធុការពរដ៏ធំធេងរបស់យើង។តែទោះបីជាយ៉ាងនេះក៏ដោយ លុះដល់ពេលវឌ្ឍនាការធំធាត់ឡើងអ្នកព្រងើយកន្តើយនឹងគុណបុណ្យរបស់យើង ងុបងុលជាមួយចិន្តាការគ្មានខ្លឹមសាររបស់អ្នក រហូតបង់បាត់សតិនិងនិរាសឆ្ងាយពីប្រាសាទអនន្តនៃម្ចាស់ជីវិតទៅស្ថិតនៅក្នុងសំណាក់នៃសបត្តជនរបស់យើង ។

## ៣០- ម្នាលទាសករនៃពិភពលោកអើយ!

រាល់ពេលអរុណរះរ៉ាយោនៃមេត្តាធម៌របស់យើងបានបក់ផាត់មកដល់រូបអ្នក តែឃើញរូបអ្នកកំពុងលង់លក់ លើខ្នមនៃក្តីប្រមាទ ដោយវ៉ាយោចំពោះសភាពរបស់អ្នក តេជវ៉ាយោក៏បានត្រឡប់មកកាន់ទេវលោកវិញ ។

## ៣១-ម្នាលបុត្រនៃលោកីយ៍អើយ!

បើអ្នកប្រាថ្នារូបយើង ចូរកុំស្វែងរកវត្ថុដទៃ បើអ្នកចង់ឃើញសោភ័ណភាពរបស់យើង ចូរអ្នកបិទកែវភ្នែករបស់អ្នកពីវត្ថុទាំងឡាយ មាននៅលើលោកនេះ ព្រោះសេចក្តីប្រាថ្នារបស់យើង និង

សេចក្ដីប្រាថ្នារបស់អ្នកខុសគ្នាបីដូចជាទឹកនិងភ្លើង មិនអាចនិតនៅជាមួយគ្នាក្នុងបេះដូងតែមួយបានឡើយ ។

## ៣២- ម្នាលជនចំឡែកដែលបានមកជាមិត្តអើយ!

ដួងពន្លឺក្នុងបេះដូងរបស់អ្នក ត្រូវបានដុតឡើងដោយដៃអានុភាពរបស់យើង ចូរកុំពន្លត់ដោយព្យុះនៃអត្តានិងកិលេសរបស់អ្នក ។ ឯឱសថទិព្វសំរាប់ព្យាបាលជម្ងឺទាំងឡាយរបស់អ្នក ចូរអ្នកចាំឱ្យជាក់ថា គឺការរំលឹកដល់រូបយើងនិងចូរយកសេចក្ដីស្រឡាញ់របស់យើងជារតនសម្បត្តិរបស់អ្នក ហើយថ្នាក់ថ្នមទុកជាកែវភ្នែកនៃជីវិតរបស់អ្នក ។

## ៣៣- ម្នាលភាតរទាំងឡាយអើយ!

ចូរអ្នកស្ដាប់ធម៌ដ៏អភិរម្យពីអារាម នៃអត្ថរសវាចាររបស់យើង និងក្រេបទឹកអម្រិតពីសមុទ្រនៃមធុរវាទរបស់យើង ចូរបណ្ដុះគ្រាប់រុក្ខជាតិនៃគតិបណ្ឌិតរបស់យើង ក្នុងថ្នាលបរិសុទ្ធនៃបេះដូងរបស់អ្នក ហើយស្រោចដោយទឹកនៃភាពទុកចិត្តដើម្បីឱ្យរុក្ខជាតិនៃគតិ

បណ្ឌិតរបស់យើង បានលូតលាស់ឡើងស្រស់ស្រាយប្រិមប្រិយ នាបុរីពិសិដ្ឋក្នុងបេះដូងរបស់អ្នក ។

## ៣៨- ម្នាលពួកទេវតានានាស្ថានសួគ៌អើយ!

យើងបានបណ្តុះរុក្ខជាតិនៃសេចក្តីស្រឡាញ់និងមិត្តភាពរបស់អ្នក នៅក្នុងឧទ្យានបរិសុទ្ធនាស្ថានសួគ៌ដោយដៃនៃសេចក្តីអាណិតអាសូរ និងស្រោចដោយទឹកនៃការថែរក្សារបស់យើង ឥឡូវនេះរដូវផ្លែផ្កាបានមកដល់ហើយ ចូរអ្នកខិតខំពិទក្សរក្សាផ្លែនៃសេចក្តីស្រឡាញ់និងមិត្តភាពនេះ ឲ្យបានរួចពីភ្លើងកិលេសនិងតណ្ហា ។

## ៣៩- ម្នាលសំឡាញ់ទាំងឡាយអើយ!

ចូរអ្នកពន្លត់ភ្លើងនៃទោសវិបត្តិនាបេះដូងរបស់អ្នក ហើយដុតភ្លើងនៃការណែនាំពីស្ថានសួគ៌ ។ ពីព្រោះក្នុងពេលឆាប់ៗនេះក្នុងនាមវត្តមានដ៏ពិសិដ្ឋនៃព្រះជាម្ចាស់ពពួកអ្នកវិភាគនិងពិនិត្យមនុស្សជាតិនឹងឈប់ទទួលនូវវត្ថុណា ក្រៅពីគុណធម៌បរិសុទ្ធ គ្មានមន្ទិលនិងវិសុទ្ធភាពជ្រះថ្លា ។

## ៣៦- ម្នាលបុត្រនៃធូលីអើយ!

អ្នកដែលឆ្លាតគេមិននិយាយ លើកលែងតែមានមនុស្សស្តាប់ បីដូចជាអ្នកកាន់ពែងទឹក គេអាចហុចបានលុះត្រាតែគេឃើញមានអ្នកស្វែងរកនិងអ្នកជាទីស្រឡាញ់ គេនឹងមិនស្រែកហៅពីជំរៅបេះដូងរបស់គេទេ ដរាបណាគេសំឡឹងឃើញសោភ័ណភាពនៃម្ចាស់ស្នេហ៍របស់ខ្លួន ។ ដូច្នេះ ចូរអ្នកផ្សាំគ្រាប់រុក្ខជាតិនៃបញ្ញានិងគតិបណ្ឌិតនេះ ក្នុងសួនច្បារនៃបេះដូងរបស់អ្នក ថែទាំដោយប្រុងប្រយត្ន័រហូតគ្រាប់រុក្ខជាតិនៃគតិបណ្ឌិតនិងបញ្ញាសួគ៌បានលូតលាស់ស្រស់បំព្រង ផុសចេញពីបេះដូងរបស់អ្នកហើយថ្នាក់ថ្នម កុំឱ្យប្រឡាក់ស្លាកស្នាមធូលី ។

## ៣៧- ម្នាលសាវ័កទាំងឡាយអើយ!

ចូរកុំបោះបង់ជីវិតរាជ្យដ៏អមតៈ ប្រាសប្រាណទៅរកពិភពអនិច្ចំ និងកុំនិរទេសខ្លួនពីអធិប្បតេយ្យភាពសួគ៌ ដើម្បីសេចក្តីប្រាថ្នាខាងលោកីយ៍របស់អ្នក ។ នេះជាជ្រោះនៃជីវិតអនន្ត ដែល

ផុសចេញពីប្រភពនៃស្លាបប៉ាកការបស់ព្រះគុណម្ចាស់។ ពិតប្រាកដណាស់សុភមង្គល នឹងកើតមានដល់អ្នកដែលបានទទួលទាន ។

## ៣៨- ម្នាលបុត្រនៃធម៌អើយ!

ចូរទំលាយទ្រុងរបស់អ្នក ហើយហើរឱ្យប្រត្យក្សទៅលើវេហាដ៏បរិសុទ្ធ បីដូចជាបក្សី *ហ៊ុំនីជ* នៃសេចក្តីស្រឡាញ់ និងគេចពីអត្តារបស់អ្នក ហើយចូលទៅស្នាក់ក្នុងពិភពនៃវិសុទ្ធភាពដែលពោរពេញទៅដោយវិញ្ញាណនិងមេត្តាធម៌ ។

## ៣៩-ម្នាលបុត្រនៃធូលីអើយ!

ចូរកុំត្រេកអរក្នុងសំណាកក្តីសប្បាយម៉្ងៃៗនេះនិងកុំជំលៀសខ្លួនពីទ្រនំអមតៈ ។ ចូរកុំដោះដូរឧទ្យានអនន្ត ជាមួយគំនរធូលីនៃលោកីយ៍ ។ ចូរចេញពីគុករបស់អ្នក ឡើងទៅកាន់វាលស្មៅដ៏រុងរឿងនិងចេញពីទ្រុងនៃអនត្តារបស់អ្នក ហើរទៅកាន់វេហាដ៏ធំល្វឹងល្វើយ ។

## ៤០- ម្នាលសាវ័កនៃធម៌អើយ!

ចូររំដោះខ្លួនរបស់អ្នកឱ្យរួចផុតពីខ្នោះលោកីយ៍និងដោះលែងវិញ្ញាណពីគុកនៃអនត្តារបស់អ្នក ។ ចូរឆក់យកឱកាសដ៏ប្រពៃនេះព្រោះមិនមានជាថ្មីទៀតទេឡើយ ។

## ៤១- ម្នាលបុត្រនៃសាវិកានៃយើងអើយ!

ប្រសិនបើអ្នកឃើញអាណាចក្រអមតៈ អ្នកនិងព្យាយាមជៀសចេញពីលោកីយ៍អនត្តានេះ។ ប៉ុន្តែ ការបិទបាំងវត្ថុម្ខាងហើយបើកឱ្យឃើញវត្ថុម្ខាង គឺជារឿងអាថ៌កំបាំង មិនមាននរណាយល់ក្រៅពីអ្នកដែលមានបេះដូងបរិសុទ្ធឡើយ ។

## ៤២- ម្នាលសាវ័កនៃយើងអើយ!

ចូរលាងជំរះបេះដូងរបស់អ្នកឱ្យស្អាតពីថ្នាលនៃសេចក្តីប្រមាទនិងសំអាតពីស្នឹមនៃសេចក្តីច្រណែននិន្ទាឱ្យបរិសុទ្ធ ហើយរូតរះចូលមកកាន់អារាមនៃភាពបរិសុទ្ធរបស់យើង ។

## ៤៣- ម្នាលសំឡាញ់ទាំងឡាយអើយ!

ចូរដើរក្នុងផ្លូវដែលព្រះដ៏ជាមិត្តពេញចិត្ត ហើយចូរចាំទុកថា សេចក្ដីស្រឡាញ់ពេញចិត្តរបស់ព្រះអង្គមានក្នុងសេចក្ដីពេញចិត្តនៃមនុស្សផងទាំងពួងរបស់ព្រះអង្គ ។ ត្រង់នេះសំដៅថាមនុស្សយើងមិនគួរចូលទៅក្នុងផ្ទះរបស់មិត្តភក្តិ លើកលែងតែមិត្តភក្តិគេពេញចិត្ត ទាំងមិនប៉ះពាល់ទ្រព្យសម្បត្តិរបស់មិត្តភក្តិ មិនប្រកាន់ឆន្ទៈរបស់ខ្លួនគ្រាន់បើជាងឆន្ទៈរបស់មិត្តភក្តិ និងមិនស្វែងរកយកប្រៀបលើមិត្តភក្តិរបស់ខ្លួន ។ ចូរសញ្ជឹងគិត ឱអ្នកដែលមានបញ្ញាអាចយល់ដឹងបានអើយ !

## ៤៤- ម្នាលសំឡាញ់នាព្រះបល្ល័ង្កនៃយើង!

ចូរអ្នកកុំស្ដាប់និងមើលវត្ថុអាក្រក់ កុំបន្ថោកខ្លួនរបស់អ្នកទាំងជង្ហើមធំនិងស្រែកឃំ ។ កុំនិយាយអាក្រក់ ដើម្បីកុំឱ្យអ្នកដទៃនិយាយតាម និងកុំពង្រើកកំហុសអ្នកដទៃ ដើម្បីបិទបាំងកំហុសរបស់ខ្លួន កុំប្រាថ្នាឱ្យអ្នកដទៃធ្លាក់ខ្លួនថោកទាប ដើម្បីភាពថោកទាបរបស់ខ្លួនមិនល្បីសុសសាយនោះ ។ ពេលវេលារបស់អ្នកនៅ

ត្រឹមមួយរយៈកំសាន្តប៉ុណ្ណោះ។ ដូច្នេះចូរធ្វើដំណើរជីវិតរបស់អ្នកឱ្យបានស្អាតស្អំ បេះដូងជ្រះថ្លា គំនិតបញ្ញានិងលក្ខណៈឧបនិស្ស័យបរិសុទ្ធគ្មានស្នាមមន្ទិលដើម្បីឱ្យរូបអ្នកមានសេរីភាពហើយរីករាយពេញចិត្តក្នុងការលះបង់រាងកាយនេះ ទៅកាន់ស្ថានសួគ៌អាថ៌កំបាំងនិងអាស្រ័យនៅក្នុងប្រាសាទអនន្តរៀងរហូត ។

## ៤៥- អនិច្ចា! ម្នាលអ្នកជាប់កិលេសអើយ!

អ្នកបានឆ្លងកាត់ព្រះដំណាក់ដ៏ជាទីសក្ការៈបីដូចជាផ្ទេកបន្ទោរនិងបេះដូងជោរជន់ដោយក្តីស្រមើស្រមៃគ្មានខ្លឹមសារ ។ អ្នកពេញចិត្តនិងលុតជង្គង់ចំពោះចិន្តាការ ដ៏រវើរវាយគ្មានខ្លឹមសាររបស់អ្នក ហើយស្រដីថាជាសច្ចធម៌ ឯក្រសែភ្នែករបស់អ្នកបាញ់ឆ្ពោះទៅរកបន្លា ហើយស្រដីថាជាផ្កាទៅវិញ ។ ជង្ហើមរបស់អ្នកគ្មានមួយជង្ហើមណាបរិសុទ្ធ ផុសចេញពីក្រសោមទ្រូងរបស់អ្នកទាំងជំនោរនៃភាពមិនជាប់ជំពាក់ ក៏មិនមានរសាត់មកពីឧទ្យាននៃបេះដូងរបស់អ្នកដែរ ។ ឱវាទណែនាំរបស់ព្រះជាទីសក្ការៈ អ្នកបានច្រានចោលទៅតាមក្រសែវាយោ និងឈ្មូសចោលពីផ្ទាំងចារឹក

នៃដួងចិត្តរបស់អ្នក ហើយបញ្ចេញសកម្មភាពបីដូចជាសត្វព្រៃ និងដំណើរជីវិតទៅតាមវាលស្មៅនៃកិលេសតណ្ហា ។

## ៤៦- ម្នាលភាតរៈអ្នករួមដំណើរអើយ!

ហេតុអ្វីក៏អ្នកព្រងើយកន្តើយ ចំពោះការរំលឹកដល់ព្រះដ៏ជាទីសក្ការៈ ហើយនឿលបំរះប្រាណ ឆ្ងាយពីព្រះភក្ត្ររបស់ព្រះអង្គ? សោភ័ណភាពដ៏ពិសិដ្ឋក្នុងប្រាសាទនៃភាពរុងរឿងអ្នកមិននាំគ្នាបែរទៅរកត្រឡប់ទៅជាអំពល់ប្រាណជាមួយការតស៊ូគ្មានប្រយោជន៍។ រសជាតិនៃដង្ហើមបរិសុទ្ធនិងប្រកបដោយក្តីករុណាបានបក់មកដល់ហើយ ប៉ុន្តែអ្នកទាំងអស់គ្នាមិនម្ចីម្នាអើពើ ធ្វើឱ្យទុក្ខវេទនានិងការឈឺចាប់គ្មានស្រាកស្រាន្ត ។ អនិច្ចាណាស់! ចំពោះរូបអ្នក និងបុគ្គលដែលដើរតាមផ្លូវរបស់អ្នក ។

## ៤៧- ម្នាលបុត្រនៃកិលេសអើយ!

ចូរហែកស្បៃនៃភាពអំនួត និងរំដោះខ្លួនរបស់អ្នកចេញពីគ្រឿងអភរណ៍នៃភាពក្រអើតក្រទម ។

## ៤៨- ម្នាលភាតរៈទាំងឡាយអើយ!

ចូរចេះអត់ធ្មត់ចំពោះគ្នាទៅវិញទៅមក និងកុំដាក់សេចក្តីប្រតិព័ទ្ធលើវត្ថុខាងក្រោម ។ កុំមោទនៈក្នុងភាពរុងរឿងរបស់អ្នក ហើយកុំអៀនខ្មាសក្នុងគ្រារអាប់អោន ។ មានបារមីរបស់យើងជាសក្ខីភាពថា គ្រប់វត្ថុទាំងឡាយត្រូវបង្កើតឡើងមកពីធូលីទាំងអស់ ហើយវត្ថុទាំងនេះក៏នឹងត្រូវយើងឱ្យ ត្រឡប់ទៅធូលីដូចដើមវិញដែរ ។

## ៤៩- ម្នាលបុត្រនៃធូលីអើយ!

ចូរប្រាប់ទៅភាគីទាំងឡាយ ពីជនទុរគតដកដង្ហើមធំនាពេលអធ្រាត ក្រែងលោភាពងប់ងុល នាំគេទៅកាន់ផ្លូវនៃភាពអន្តរាយ និងព្រាត់ឆ្ងាយពីព្រឹក្សានៃសម្បត្តិ ។ ការឱ្យទាននិងការមានសទ្ធាជ្រះថ្លា ជាកាយវិការនិងគុណសម្បត្តិរបស់យើង ។ ដូច្នេះសេចក្តីសុខចំរើននឹងកើតមានដល់អ្នកដែលប្រដាប់លំអខ្លួន ដោយគុណធម៌របស់យើង ។

## ៥០- ម្នាលខ្ញីមសារនៃកិលេសអើយ!

ចូរបោះបង់ការលោភលន់ចង់បានទ្រព្យគេ ហើយចាប់យកក្ដីសប្បុរសមេត្ដា ។ ព្រោះអ្នកលោភលន់ រមែងវិនាសជាហូរហែរ ឯអ្នកមានចិត្ដសប្បុរសមេត្ដា រមែងក្លាយជាទីស្រឡាញ់និងពេញចិត្ដរាប់អានពីអ្នកដទៃ ។

## ៥១- ម្នាលបុត្រនៃសាវិកានៃយើងអើយ!

ចូរកុំព្រួយក្នុងភាពក្រីក្រ និងកុំទុកចិត្ដក្នុងក្ដីសម្បូរណ៍ ។ ព្រោះភាពក្រីក្រនឹងអន្ទោលមកតាមដោយភាពសម្បូរណ៍ ឯភាពសម្បូរណ៍នឹងអន្ទោលមកតាមដោយភាពក្រីក្រ ។ ការក្រវត្ថុទាំងឡាយក្រៅពីព្រះជាម្ចាស់ វត្ថុទាំងនេះជាអំណោយដ៏ពិសេសណាស់ ចូរអ្នកកុំមើលងាយមើលថោក ព្រោះទីបំផុតភាពក្រីក្រនេះ នឹងធ្វើឱ្យអ្នកសម្បូរណ៍ក្នុងព្រះជាម្ចាស់ ហើយអ្នកនឹងយល់នូវអត្ថន័យនៃឱវាទមួយដែលថា " អ្នកជាបុគ្គលដែលក្រីក្រពិតប្រាកដ " និងនៅក្នុងព្រះធម្មលិខិតមួយបានចែងថា "ព្រះជាម្ចាស់គឺជាអ្នកមានគ្រប់វត្ថុទាំងពួង " ដូច្នេះរូបអ្នក វាហាក់បីដូចជា ដួងព្រះអរុ

ណ្ឌាទ័យ ដែលអាចសាចជះរស្មីដ៏ចិញ្ចាចចិញ្ចែងពីជើងមេឃ នៃបេះដូងរបស់អ្នកដែលស្រឡាញ់ ហើយក៏ជាអ្នកដែលអាចអាស្រ័យទៅលើបល្ល័ង្កនៃសម្បត្តិយ៉ាងសុខសាន្តភិរម្យ ។

## ៥២- ម្នាលបុត្រនៃកិលេសនិងតណ្ហាអើយ!

អ្នកព្រមឱ្យមារសត្រូវរបស់យើងចូលមកលុកលុយក្នុងផ្ទះរបស់យើង ហើយបានបណ្តេញកល្យាណមិត្តរបស់យើងចេញ ព្រោះបេះដូងរបស់អ្នកបានជំពាក់ ទៅដោយសេចក្តីស្នេហារបស់អ្នកដទៃ។ចូរស្តាប់ឱវាទរបស់ព្រះដែលជាមិត្តរបស់អ្នក ហើយបែរមុខឆ្ពោះទៅរកស្ថានសួគ៌របស់ព្រះអង្គ ។ មិត្តសំឡាញ់ខាងលោកីយ៍ស្វែងរកប្រយោជន៍របស់ខ្លួន តែក្លែងធ្វើដូចជាស្រឡាញ់គ្នាណាស់ ចំណែកឯ កល្យាណមិត្តខាងធម៌ស្រឡាញ់អ្នកហើយ គឺដើម្បីប្រយោជន៍របស់អ្នក ។ ពិតប្រាកដណាស់! ព្រះអង្គស៊ូទ្រាំរងទុក្ខលំបាកជាច្រើនអនេកប្បការណាស់ ដើម្បីនាំផ្លូវអ្នក ដូច្នេះចូរអ្នកកុំប្រទូស្តរាយនិងកុំទុរយសចំពោះព្រះអង្គ ហើយចូរប្រញាប់ទៅរកព្រះអង្គ ។ ព្រះធម៌ទាំងអស់នេះ គឺជាដួងព្រះទិន្នករនៃសច្ចធម៌

និងភក្តីភាពពិតប្រាកដដែលរះឡើងពីដើងមេឃ នៃស្លាបប៉ាកការបស់ព្រះជាម្ចាស់នៃសភាវទាំងពួង ។ ចូរត្រងត្រាប់ស្តាប់ នោះអ្នកនឹងអាចបានឮសូរស័ព្ទនៃធម៌របស់ព្រះអង្គ ព្រះអង្គជាអ្នកជួយរំដោះទុក្ខភ័យនៃសត្វលោកនិងគង់នៅដោយបារមីនៃព្រះអង្គឯង។

## ៥៣- ម្នាលអ្នកដែលមោទនខ្លួន លើគំនរទ្រព្យសម្បត្តិលោកីយ៍អើយ !

ចូរអ្នកចាំទុកថា ទ្រព្យសម្បត្តិ គឺជារនាំងឧបសគ្គមួយដ៏ធំរវាងអ្នកស្វែងរកនិងអ្នកដែលត្រូវតាមរក រវាងអ្នកដែលស្រឡាញ់និងម្ចាស់ស្នេហ៍របស់គេ ។ ភោគជនតិចណាស់បានឈានទៅដល់ទីប្រថាប់របស់ព្រះជាម្ចាស់ និងចូលទៅដល់បុរីនៃការពេញចិត្តនិងការយល់ព្រមប្រតិបត្តិតាម ។ ដូច្នេះសូមអនុមោទនាដល់ភោគជនទាំងឡាយដែលមិនត្រូវបានរនាំងទ្រព្យបិទបាំងនិងពង្រាត់ពីអាណាចក្រអនន្ត ។ ដោយបរមនាមដ៏ប្រសើរបំផុត ធ្វើជាសក្ខីភាពថា រស្មីរុងរឿងរបស់បុគ្គលដូចដែលបានពោលនេះនឹងអាចជះ

ពន្លឺដល់ពពួកទេព្តា ដែលអាស្រ័យនៅស្ថានសួគ៌ បីដូចដួងព្រះទិន្នករ បញ្ចាំងរស្មីដល់មនុស្សជាតិលើផែនដី ។

## ៥៤- ម្នាលភោគជននៅលើផែនដីអើយ !

ជនទុរគតគឺជាមនុស្សដែលយើងផ្ញើទុកជាមួយអ្នកចូរថែរក្សាមនុស្សដែលយើងបន្ទុកបណ្ដាក់នេះ គប្បីកុំចាប់អារម្មណ៍ចំពោះតែការសប្បាយរបស់ខ្លួន ។

## ៥៥- ម្នាលបុត្រដ៏ជាទីស្រឡាញ់អើយ !

ចូរជំរះខ្លួនរបស់អ្នកឱ្យបានបរិសុទ្ធ ពីឧបក្កិលេសនៃសម្បត្តិរបស់អ្នក ហើយចូលមកកាន់ពិភពនៃលទ្ធភាព ដោយចិត្តដែលប្រកបដោយសេចក្ដីស្ងប់សុខ នោះអ្នកនឹងបានក្រេបរសជាតិទឹកអម្រិតនៃជីវិតអនន្ត ពីក្រសែជ្រោះនៃភាពមិនជាប់ជំពាក់ ។

## ៥៦- ម្នាលបុត្រដ៏ជាទីស្រឡាញ់អើយ !

ការសេពគប់ជាមួយមនុស្សគ្មានធម៌ រមែងបង្កើនភាពសោកសង្រេង តែការចងមិត្តភាពជាមួយអ្នកមានធម៌អាចជំរះស្លាកស្នាម

មន្ទិលទាំងឡាយចេញពីបេះដូងបាន ។ អ្នកដែលបានព្យាយាមប្រាស្រ័យទាក់ទងជាមួយព្រះជាម្ចាស់សូមឱ្យគេចងមិត្តជាមួយបណ្តាអ្នកដែលស្រឡាញ់ព្រះអង្គហើយអ្នកដែលត្រូវការស្តាប់ធម៌របស់ព្រះជាម្ចាស់ សូមឱ្យគេព្យាយាមស្តាប់ឱវាទនៃអ្នកដែលព្រះអង្គជ្រើសបញ្ជូនមក ។

## ៥៧- ម្នាលបុត្រនៃធូលីអើយ !

ចូរប្រយត្ន័កុំដើរជាមួយបុគ្គលដែលនិរាសធម៌ និងស្វែងរកសម្ព័ន្ធភាពជាមួយពួកគេ ។ ព្រោះការចងមិត្តដូចដែលបានពោលនេះ រមែងប្តូរផ្លាស់រស្មីដួងចិត្តឱ្យកើតជាភ្លើងនរក ។

## ៥៨- ម្នាលបុត្រនៃសាវិការបស់យើងអើយ!

ប្រសិនបើអ្នកប្រាថ្នាពរសព្ទសាធុការ ពីព្រះវិញ្ញាណបរិសុទ្ធចូរធ្វើជាមិត្តរបស់បុគ្គលដែលមានធម៌ ។ ព្រោះគេបានក្រេបរសជាតិទឹកអម្រឹតពីពែងនៃជីវិតអនន្ត ដោយដៃនៃអ្នកកាន់ពែងអមតៈ ដែលបីដូចជារស្មីអរុណជាស់ដួងចិត្តរបស់មនុស្សស្លាប់ ។

## ៥៩- ម្នាលបុត្រនៃកិលេសអើយ!

គប្បីកុំគិតថាការសំងាត់ក្នុងបេះដូងរបស់អ្នក មិនមាននរណាដឹងឱ្យសោះ ។ មិនត្រឹមតែប៉ុណ្ណោះទេ ចូរចាំទុកថា ការសំងាត់ទាំងអស់នោះ ត្រូវចារឹកទុកជាតួអក្សរយ៉ាងច្បាស់ក្រឡែត និងប្រត្យក្សច្បាស់ណាស់សំរាប់យើង ។

## ៦០- ម្នាលសំឡាញ់ទាំងឡាយអើយ!

ពិតប្រាកដណាស់អ្វីក៏ដោយដែលអ្នកលាក់បាំងទុកក្នុងបេះដូងរបស់អ្នក សំរាប់យើងចាំងឆ្លុះប្រត្យក្សបីដូចជាថ្ងៃរះ តែអ្វីដែលអ្នកនៅតែលាក់បំបាំងបាននោះ គឺមកពីក្តីករុណារបស់យើង មិនមែនជារឿងគ្រាន់បើរបស់អ្នកទេ ។

## ៦១- ម្នាលបុត្រនៃមនុស្សអើយ!

មហាសមុទ្រនៃក្តីអាណិតអាសូរ ដែលវាស់វែងមិនបានរបស់យើងនោះ បានផ្តល់ដំណក់សន្សើមដល់ប្រជាករ លើផែនពិភពលោកហើយ តែមិនឃើញមាននរណាមកទទួលសោះ ។ មិនតែប៉ុណ្ណោះ គេទាំងអស់គ្នាបានងាកចេញពីទឹកអម្រឹតនៃសាមគ្គីភាព

បែរទៅរកកករនៃភាពស្មោកគ្រោក ពួកគេបានចោលពែងទឹកនៃសោភ័ណភាពអមតៈ ឈ្ងោកមុខទៅត្រេកសប្បាយជាមួយកែវទឹកលោកីយ៍ ។ អ្វីដែលគេពេញចិត្តចំជាអាប់អន់ជាទីបំផុត!

## ៦២- ម្នាលបុត្រនៃធូលីអើយ!

កុំងាកក្រសែភ្នែកចេញពីទឹកអម្រឹតនៃព្រះជាទីសក្ការៈនិងអមតហើយកុំសំលឹងមើលកករទឹកស្មោកគ្រោកនៃលោកីយ៍ តែចូរទទួលយកពែងនៃទឹកដែលយាងចុះមកពីស្ថានសួគ៌ ។ ដូច្នេះគតិបណ្ឌិតនិងសតិបញ្ញាទាំងឡាយអាចក្លាយជារបស់អ្នក ដោយប្រការនេះហើយ អ្នកអាចស្តាប់ឮសំលេងអាថ៌កំបាំង ដែលជង្ហោយហៅមកពីអាណាចក្រដែលកំបាំងពីភ្នែកមនុស្ស ហើយចូរស្រែកឱ្យឮថាហេតុអ្វីបានជារូបអ្នកងាកចេញពីទឹកអម្រឹតដ៏អមតៈរបស់យើង បែរជាទៅរកទឹកស្មោករោគមិនចិតថេរ ។

## ៦៣- ម្នាលប្រជាពលលោកទាំងឡាយអើយ!

ចូរចាំទុកថា វិបត្តិភ័យដែលស្មានមិនដល់កំពុងអន្ទោលតាមរកអ្នក ឯទណ្ឌកម្មដ៏ជំណាំកំពុងរងចាំអ្នក កុំគិតថាការប្រព្រឹត្តិ

របស់អ្នកអាចកំបាំងពីទស្សនៈរបស់យើងបានឱ្យសោះ។ មានសោភ័ណភាពរបស់យើងជាសក្ខីភាពថា: គ្រប់ទង្វើទាំងឡាយរបស់អ្នកនោះ ស្លាបប៉ាកការបស់យើងបានចារឹកជាអក្ខរយ៉ាងប្រត្យក្ស លើផ្ទាំងទេព្វមរកត ។

## ៦៤- ម្នាលអធិរាជហឹង្សាអើយ!

ចូរដកដៃរបស់អ្នកពីការជិះជាន់គាបសង្កត់ ព្រោះយើងបានកំណត់ទុកនៅក្នុងបដិញ្ញាហើយថា មិនករុណាដល់អ្នកប្រើអំពើហឹង្សានិងអយុត្តិធម៌ឡើយ ។ បដិញ្ញារបស់យើងនេះ មិនអាចកែប្រែបានឡើយ។ ព្រោះត្រូវបានលិខិតទុកក្នុងធម្មចារឹក និងប្រថាប់ដោយព្រះសង្ហារនៃភាពរុងរឿងរបស់យើង ។

## ៦៥- ម្នាលជនអនាវ្យធម៌អើយ!

ភាពអត់ធ្មត់របស់យើង បានធ្វើឱ្យអ្នកកាន់តែហ៊ាននិងបានចិត្ត ហើយការខន្តីស៊ូទ្រាំរងទុក្ខវេទនាជាយូរអង្វែងរបស់យើង បានធ្វើឱ្យអ្នកប្រាសចាកនិងធ្លាក់ក្នុងក្តីប្រមាទ រហូតភ្លើងកិលេសរបស់អ្នក

ឆេះត្រគោលឡើងលើផ្លូវដ៏គ្រោះថ្នាក់ ដែលអាចនាំឆ្ពោះទៅដល់មហន្តរាយដ៏ធំមួយ ។

## ៦៦- ម្នាលនិរប្រវេសន្តទាំងឡាយអើយ!

អណ្តាតដែលយើងបានតាក់តែងឱ្យអ្នកនោះ សំរាប់តែរំលឹកដល់យើង ចូរកុំឱ្យប្រឡាក់ដោយក្តីច្រណែននិន្ទា ប្រសិនបើភ្លើងនៃអនត្តា គ្របដណ្តប់លើរូបអ្នក ចូររកនឹកពីគុណវិបត្តិរបស់អ្នក មិនមែនជាកំហុសនៃសន្តនិករបស់យើងទេ ។ ព្រោះថា មនុស្សម្នាក់ៗ ស្គាល់ខ្លួនឯងច្បាស់ជាងស្គាល់អ្នកដទៃ ។

## ៦៧- ម្នាលបុត្រនៃក្តីរវើរវាយអើយ!

ចូរចាំទុកថា ពេលដែលដួងអរុណោទ័យបញ្ចាំងរស្មីពីជើងមេឃនៃភាពបរិសុទ្ធអនន្ត អំពើនឹងការសំងាត់ដ៏ស្មោកគ្រោកដែលអ្នកបានប្រព្រឹត្តនៅទីកំបាំងនោះ នឹងត្រូវលាតត្រដាងចំពោះមុខប្រជាពលលោកទាំងអស់ ។

## ៦៨- ម្នាលរុក្ខជាតិដែលដុះចេញពីធូលីអើយ!

ហេតុអ្វីដែដ៏ស្មោកគ្រោករបស់អ្នកមិនអាចកាន់គ្រឿងអភិរណ៍របស់អ្នកជាមុន និងហេតុដូចម្ដេច បេះដូងដែលប្រឡាក់ដោយកិលេសនិងតណ្ហារបស់អ្នក ព្យាយាមចូលមកកាន់អាណាចក្រដ៏ពិសិដ្ឋ និងប្រាស្រ័យទាក់ទងជាមួយយើង ។ វត្ថុដែលអ្នកប្រាថ្នានោះហាក់បីដូចជានៅឆ្ងាយពីអ្នកណាស់ ។

## ៦៩- ម្នាលបុត្រនៃអាដាំអើយ!

វចីសុចរិតនិងទង្វើសុចរិត អាចបានទៅដល់ស្ថានសួគ៌ដ៏រុងរឿង ។ ចូរព្យាយាមប្រព្រឹត្តនូវអំពើសុចរិត ឱ្យបានផុតពីអត្តានិងការមានពុតត្បុតអាក្រក់ ហើយធ្វើខ្លួនឱ្យក្លាយជាទីប្រោសប្រាណពីរាជដំណាក់នៃភាពរុងរឿង។ ព្រោះក្នុងរយៈពេលមិនយូរនេះ នៅចំពោះមុខព្រះដ៏ជាទីសក្ការៈ អ្នកធ្វើវិភាគមនុស្សលោក និងមិនទទួលយកវត្ថុណា ក្រៅពីគុណធម៌បរិសុទ្ធ និងទង្វើវិមលភាព ។ នេះគឺជាដួងអរុណោទ័យនៃអច្ឆរិយគតិ និងជាភាពអាថ៌កំបាំងសួគ៌ ដែលសាចរស្មីពីជើងមេឃនៃព្រះរាជបំណង

ខាងលើ ។ ដូច្នេះ ព្រះពរអាចកើតមានដល់ជន្ទានុជនណា ដែលប្រព្រឹត្តតាម ។

## ៧០- ម្នាលបុត្រនៃលោកិយអើយ!

ភាវៈនៃជីវិតនោះអភិរម្យណាស់ បើអ្នកបានសំរេចដល់ ឯអាណាចក្រនៃអនន្តភាពនោះសែនរុងរឿងណាស់ បើអ្នកឆ្លងផុតពីសង្ខារលោកិយនេះ ។ ភាពបីតិបរិសុទ្ធនោះផ្អែមណាស់ ប្រសិនបើអ្នកបានក្រេបពីដៃទេវបុត្រ និងបើសិនអ្នកបានសំរេចដល់សភាវនោះ អ្នកនឹងមានឥស្សរៈពីហាយនភាព និងមរណៈនៃទុក្ខសោកទាំងពួង ។

## ៧១- ម្នាលសំលាញ់អើយ!

ចូរនឹកដល់បដិញ្ញា ដែលអ្នកបានសន្យាជាមួយយើង លើ *គិរីប៉ារ៉ាន* ក្នុងអាណាបរិវេណដ៏បរិសុទ្ធ នា*ហ្សាម៉ាន* ។ យើងបានឱ្យពពួកទេព្តា និងពពួកទេពទាំងឡាយដែលអាស្រ័យនៅក្នុងអមរបុរីមកធ្វើជាសក្ខីភាពនោះ មកទល់នឹងពេលនេះមិនឃើញមាននរណាម្នាក់នៅស្មោះត្រង់ចំពោះបដិញ្ញាឡើយ ។ ពិតប្រាកដ

ណាស់ មោទនភាពនិងចរិតអប្រិយទុរយសបានលុបបជិញ្ញានេះចេញពីកំផែងបេះដូងរបស់អ្នកគ្មានសល់ សូម្បីស្លាកស្នាមឡើយ។ ទោះបីជាយើងឈ្វេងដឹងក៏យើងនៅរងចាំនិងមិនលាតត្រដាងដែរ។

## ៧២- ម្នាលសាវ័កអើយ!

អ្នកបីដូចជាព្រះខ័ន ដែលត្រូវលត់ឡើងយ៉ាងល្អប្រណិតលាក់ទុកក្នុងភាពងងឹតរបស់ស្រោម ធ្វើឱ្យគុណតំលៃនៃស្នាដៃរបស់ជាងត្រូវស្ថិតនៅជាកំបាំង ។ ដូច្នេះ ចូរអ្នកចេញពីស្រោមកិលេសនិងអត្តារបស់អ្នកមកនេះ ដើម្បីឱ្យគុណតំលៃរបស់អ្នក លេចប្រត្យក្សឡើង និងជះរស្មីលើភពទាំងអស់ ។

## ៧៣- ម្នាលសំលាញ់នៃយើងអើយ!

អ្នកជាដួងអរុណ្ណោទ័យ លើនភាល័យនៃភាពបរិសុទ្ធរបស់យើង ចូរកុំបណ្តោយឱ្យកិលេសលោកិយបិទបាំងរស្មីរបស់អ្នក ។ ចូហែកស្បៃនៃកិលេសនេះឱ្យអស់ ហើយរះចេញមកឱ្យប្រត្យក្សច្បាស់ និងជះរស្មីជីវិតលើគ្រប់វត្ថុទាំងពួង ។

## ៧៤- ម្នាលបុត្រនៃមោទនភាពអើយ!

ចូរកុំបោះបង់វិជិតរាជ្យអនន្ត ដើម្បីអធិបតេយ្យភាពមិនទៀងទាត់ និងកុំលំអខ្លួនជាមួយពណ៌លោកិយ មកប្រើជាគ្រឿងអំនួតរបស់អ្នក ។ មានសោភ័ណភាពរបស់យើងជាសក្ខីភាពថា: យើងនឹងលុបពណ៌លោកិយនៃភាពផ្សេងគ្នាទាំងអស់នេះ ហើយប្រមូលទុកក្នុងដីឱ្យក្លាយត្រឹមពណ៌តែមួយ លើកលែងតែពពួកអ្នកដែលជ្រើសយកពណ៌របស់យើង និងមិនប្រឡាក់ប្រឡូកជាមួយពណ៌ដទៃ ។

## ៧៥- ម្នាលបុត្រនៃក្តីប្រមាទអើយ!

ចូរកុំប្រតិពទ្ធ័ជាមួយអធិបតេយ្យភាពលោកិយ និងកុំត្រេកសប្បាយជាមួយសំភារៈនៃពិភពលោកនេះ ។ អ្នកហាក់បីដូចជាបក្សីដែលខ្សៀវខ្វារ លើគុម្ពោតព្រៃដែលគ្មានគិត លុះដល់ព្រានមច្ចុរាជបាញ់ធ្លាក់មកដល់ដី រំពេចនោះរូបឆោមពណ៌សម្បុរ និងសំនៀងក៏ត្រូវក្សយទៅដែរ មិនសេសសល់សូម្បីតែស្លាកស្នាម ។ ម្នាលទាសករកិលេសអើយ ចូរភ្ញាក់ខ្លួនឡើង!

# ៧៦- ម្នាលបុត្រនៃសាវិកាអើយ!

ការណែនាំស្តាប់ផ្ទាល់ដោយសំដីឥឡូវនេះត្រូវបានផ្តល់ដោយការប្រព្រឹត្តិ ។ អ្នកទាំងអស់គ្នាត្រូវសំដែងចេញ នូវទង្វើដែលបរិសុទ្ធនិងជ្រះថ្លា ។ ពីព្រោះការប្រព្រឹត្តិមានតែនៅក្នុងអ្នកដែលយើងស្រឡាញ់ប៉ុណ្ណោះ ។ ដូច្នេះ ចូរអ្នកប្រឹងឱ្យអស់ពីដួងចិត្តនិងវិញ្ញាណ ដើម្បីឱ្យការប្រព្រឹត្តិរបស់អ្នក លេចប្រត្យក្សឡើង ។ នេះគឺជាឱវាទដែលយើងទុកសំរាប់អ្នក ក្នុងធម្មចារឹកដ៏ពិសិដ្ឋ និងរុងរឿង ។

# ៧៧- ម្នាលបុត្រនៃសេចក្តីយុត្តិធម៌អើយ!

នាយាមរាត្រីមួយ ទេវទូតរបស់ព្រះជាម្ចាស់ទ្រង់ចុះពីកំពូលមរកតនៃសច្ចធម៌ មកកាន់ *សាដ្រាទូម៉េនបាហា* ទ្រង់ពិលាបខ្សឹកខ្សួលរហូតដល់ពពួកទេវតានិងទេពអប្សរទាំងឡាយ ដែលប្រាស័យនៅក្នុងស្ថានសួគ៌នោះ ទ្រង់សោកពិលាបដោយសារការខ្សឹកខ្សួលរបស់ព្រះអង្គ ។ គ្រានោះមានសំឡេងមួយបន្លឺឡើងថា: ហេតុអ្វីបានជាពពួកអ្នកនាំគ្នាសោកពិលាបយ៉ាងនេះ? ទេវទូតទ្រង់បានតប

ថា ខ្ញុំម្ចាស់ត្រូវបានតំរូវឱ្យយាងទៅរងចាំប្រមើលមើល លើភ្នំសច្ចធម៌ ដើម្បីស្រូបយកសុគន្ធានៃសេចក្តីស្មោះត្រង់ តែមិនឃើញមានមកពីឋានមនុស្សសោះ លុះខ្ញុំម្ចាស់ត្រូវហៅឱ្យត្រឡប់មកវិញស្រាប់តែឃើញបក្សីនៃភាពបរិសុទ្ធ ត្រូវជាប់ក្នុងក្រញាំសុនខ លើផែនដីយ៉ាងឈឺចាប់។ ក្នុងនោះពពួកទេពអប្សរទាំងឡាយបានម្នីម្នាចេញពីនិវេសនដ្ឋានអាថ៌កំបាំង ហើយសួររកឈ្មោះរបស់ពួកគេ រហូតបានជ្រាបអស់លើកលែងតែឈ្មោះមួយ ។ លុះដល់ ជជីកសួរទៅអក្សរទីមួយត្រូវបានបន្លឺឡើង គ្រានោះផងដែរ ពពួកអ្នកដែលអាស្រ័យនៅក្នុងទេពវិមាននោះ បានប្រញាប់ប្រញាល់ចេញមកពីបន្ទប់ដ៏ពិសិដ្ឋរហូតដល់អក្សរទីពីរបានបង្ហាញឡើងមកពួកគេក៏ដួលរលំភ្លាម ។ គ្រានោះមានសំលេងមួយមកពីទីសក្ការៈខាងក្នុងបន្លឺថា " ប៉ុណ្ណឹងបានហើយ " តាមពិតរឿងដែលពួកគេធ្លាប់បានប្រព្រឹត្តនិងកំពុងធ្វើនៅពេលនេះ យើងបានឈ្វេងយល់អស់ហើយ ។

## ៧៨- ម្នាលបុត្រនៃសាវិកាអើយ!

ចូរក្រេបទឹកអម្រឹតនៃភាពអាថ៌កំបាំង ដែលហូរមកពីវចីវាចារបស់ព្រះករុណាធិគុណម្ចាស់ ហើយសំលឹងទៅកាន់ដួងព្រះអាទិត្យនៃបញ្ញាពីអរុណោទ័យនៃអច្ឆរិយគតិសួគ៌។ ចូរបណ្តុះគ្រាប់រុក្ខជាតិនៃគតិបណ្ឌិតរបស់យើង ក្នុងថ្នាលបរិសុទ្ធនៃបេះដូងរបស់អ្នកហើយ ស្រោចដោយទឹកនៃការទុកចិត្ត ដើម្បីឱ្យរុក្ខជាតិនៃបញ្ញានិងគតិបណ្ឌិតបានដុះលូតលាស់ឡើងស្រស់បំព្រង ក្នុងបុរីពិសិដ្ឋនៃបេះដូងរបស់អ្នក ។

## ៧៩- ម្នាលបុត្រនៃកិលេសអើយ!

តើអ្នកនឹងហោះហើរលើកិលេសលោកីយ៍ ដល់ណាទៀត? ស្លាបដែលយើងបានអោយដល់អ្នក ទុកសំរាប់ហើរទៅកាន់ភពបរិសុទ្ធអាថ៌កំបាំង មិនមែនហើរទទាំងទៅកាន់ដែនស្រមើស្រមៃគ្មានប្រយោជន៍នោះទេ ឯសិត្ថដែលយើងបានកំណត់ឱ្យអ្នកក៏សំរាប់តាក់តែងលំអផ្នត់កេសារបស់យើង មិនមែនឱ្យនាំមកកោរសិរសានៃយើងទេ ។

## ៨០- ម្នាលអ្នកសាវ័កសាវិកាទាំងឡាយអើយ!

អ្នកគឺជាព្រឹក្សាក្នុងផល្លារាមរបស់យើង ចូរអ្នកផ្តល់ផលឱ្យល្អប្រសើរសំរាប់ខ្លួនអ្នក និងអ្នកដទៃបានទទួលប្រយោជន៍ពីព្រឹក្សានោះ ។ ម្នាលអ្នកមានបញ្ញាអើយ! វាជាតួនាទីរបស់មនុស្សគ្រប់រូបត្រូវប្រកបអាជីវៈនិងមុខរបរ ។ ដោយក្នុងនោះបានបង្កប់នូវការសំងាត់នៃសម្បត្តិ ។ ព្រោះលទ្ធផលដែលអាស្រ័យលើមធ្យោបាយនិងក្តីករុណារបស់ព្រះជាម្ចាស់ វាមានភាពគ្រប់គ្រាន់សំរាប់អ្នកគ្រប់គ្នា ។ ដើមឈើដែលមិនមានផល វាសក្តិសមណាស់សំរាប់ភ្លក់ភ្លើង ។

## ៨១- ម្នាលសាវ័កទាំងឡាយអើយ!

មនុស្សដែលអន់បំផុត គឺអ្នកដែលគ្មានផ្តល់ផ្លែផ្កាបន្តិចបន្តួចនៅលើលោកនេះ ។ ពិតប្រាកដណាស់ មនុស្សដូចដែលបានពោលនេះ ត្រូវគេចាត់ទុកជាសាកសព ។ តែនៅក្នុងក្រសែចក្ខុរបស់ព្រះជាម្ចាស់ សាកសពនេះ នៅប្រសើរជាងអ្នកដែលខ្ជិលច្រអូសគ្មានតំលៃ ។

## ៨២- ម្នាលសាវ័កទាំងឡាយអើយ!

មនុស្សដែលល្អបំផុតគឺអ្នកដែលរកកំរៃចិញ្ចឹមជីវិតពីការប្រកបមុខរបររបស់ខ្លួន ហើយប្រើប្រាស់សំរាប់ខ្លួននិងញាតិមិត្តបងប្អូនដោយសេចក្តីស្រឡាញ់ក្នុងនាមព្រះជាម្ចាស់ ដែលជាបរមក្សត្រនៃភពទាំងពួង ។

ដោយសេចក្ដីករុណារបស់ព្រះជាម្ចាស់ ព្រះធម៌អាថ៌កំបាំងនេះត្រូវបានប្រសូតឡើងយ៉ាងសុក្រិត បង្ហាញពីសោភ័ណភាពនិងព្រះទ័យដ៏យកចិត្តទុកដាក់របស់ព្រះអង្គ ដល់មនុស្សសត្វទាំងអស់ដែលព្រះអង្គតាក់តែងមក ។

ឱសំឡាញ់ទាំងឡាយអើយ! យើងសូមធ្វើជាសក្ខីភាពថា: សេចក្ដីករុណាបរិបូរណ៍ហើយការសំដែងហេតុផលក៏សន្ធតថាអស់សេចក្ដី ហើយបទពិសោធក៏ប្រត្យក្សច្បាស់ហើយ ភស្តុតាងក៏បានលាតត្រដាងយ៉ាងប្រាកដហើយដែរ ។ ឥឡូវនេះនៅសល់តែសេចក្ដីព្យាយាមរបស់អ្នកលើដំណើរផ្លូវមិនជាប់ជំពាក់ អាចសម្រេចផលបានប៉ុណ្ណោ ។ នេះគឺជាវិធីធម៌ដែលព្រះជាម្ចាស់ទ្រង់ប្រោសប្រណីដល់អ្នកនិងបណ្ដាអ្នកអាស្រ័យនៅក្នុងស្ថានសួគ៌ និងលើផែនដី ។ សូមថ្វាយនូវឧត្ដុំសនាចំពោះព្រះអង្គ ទ្រង់ជាម្ចាស់នៃភពទាំងពួង។

-ព្រះសាស្ដាបាហាអ៊ុលឡាហ៍